យល់ថា ត្រូវតែបោះចោលឬលក់របស់នេះចេញទៅ ជាជាងទុកឱ្យម្តាយភ័យខ្លាចស្ទើរស្លាប់ដូច្នេះ តែកាលណាយើងប៉ះវត្ថុនេះ ។ ហើយម្យ៉ាងទៀតបើកូនជឿម្តាយ កូនត្រូវដោះចិញ្ចៀននេះចេញដែរ យើងមិនត្រូវចងស្ពានមេត្រីជាមួយនឹងពួកអារក្សទេ ព្រោះវានេះសុទ្ធតែខ្មោចបិសាច ។ ឯខ្មោចបិសាចនេះព្រះម្ចាស់សួគ៌ បានសម្តែងហើយថាវាយ៉ាងដូចម្តេចខ្លះនោះ" ។

អាឡាដាំងក៏ឆ្លើយតបថា : "អ្នកម្តាយ ! ខ្ញុំសុំអនុញ្ញាតអ្នកម្តាយជាមុនថា កូនពុំព្រមលក់ចង្កៀងនេះទេ ទោះកូនប្រុងនឹងលក់ក៏ដោយ ព្រោះចង្កៀងនេះមានប្រយោជន៍ទាំងខ្ញុំទាំងអ្នកម្តាយ ។ អ្នកម្តាយពុំបានឃើញទេឬ យើងត្រូវតែទុកឱ្យចង្កៀងរកផលផ្តល់ឱ្យយើងទៀត ដើម្បីនឹងយើងបានចិញ្ចឹមជីវិត និងថែរក្សាខ្លួនយើងផង ។ សូមអ្នកម្តាយពិចារណាដូចខ្ញុំផងថា មិនមែនឥតហេតុផលទេ ដែលមេធ្មប់កំណាចក្លែងក្លាយនេះ ខំចំណាយកម្លាំងធ្វើដំណើរយ៉ាងឆ្ងាយ ហើយលំបាកដូច្នេះ គឺពិតជាវាចង់បានចង្កៀងទិព្វនេះហើយៗ ដែលវាដឹងច្បាស់ថា នឹងបានមាសប្រាក់យ៉ាងច្រើនពុំខាន ដែលសព្វថ្ងៃមាសប្រាក់ទាំងនោះនៅក្នុងបន្ទប់ក្នុងដីនៅឡើយ ។ ការណ៍នេះពិតមែន ព្រោះកូនបានឃើញវត្ថុនេះ ផ្ទាល់នឹងភ្នែកដូចគាត់បានពោល ។ មេធ្មប់ស្គាល់ច្បាស់ណាស់នូវហិតប្រយោជន៍និងតម្លៃរបស់នេះ ។ ឥឡូវ បើព្រេងវាសនាយើងបានប្រាប់យើងឱ្យស្គាល់គុណសម្បត្តិនៃចង្កៀងនេះហើយ.



យើងត្រូវទុកចង្កៀងនេះប្រើ ប៉ុន្តែគ្រាន់តែប្រយ័ត្នកុំឱ្យលេចឮទៅក្រៅ នាំឱ្យអ្នកផងច្រណែននិន្ទានឹងយើង ។ ឯរឿងចង្កៀង កូននឹងយកចេញពីមុខម្តាយភ្លាម ទៅទុកនៅកន្លែងណាមួយ ដែលកូនអាចរកឃើញទាន់ចិត្តនៅពេលត្រូវការ. ព្រោះអ្នកម្តាយមិនហ៊ានទុកនៅជិតខ្លួន ខ្លាចអារក្សវាមកសួរទៀត ។ ចំណែកចិញ្ចៀនខ្ញុំមិនដោះចេញទេ ។ បើកុំតែបានចិញ្ចៀននេះនោះអ្នកម្តាយលែងបានឃើញមុខកូនហើយ ។ បើសិនជាចិញ្ចៀននេះនៅនោះ ខ្ញុំនឹងរស់នៅយូរអង្វែងតទៅទៀត ។ ហេតុនេះ. សូមអ្នកម្តាយអនុញ្ញាតឱ្យកូនពាក់ចិញ្ចៀននេះ នៅនឹងម្រាមដៃជានិច្ច ។ តើអ្នកណាមួយអាចដឹងថា ខ្ញុំនឹងឥតមានគ្រោះថ្នាក់អ្វីទៀតទេទៅថ្ងៃមុខ ហើយបើសិនជាមានគ្រោះ តើនរណាមួយអាចជួយយកអាសាខ្ញុំទោះបីខ្លួនអ្នកម្តាយក្តីខ្ញុំក្តី? ដោយការយល់របស់អាឡាដាំងនេះសមហេតុសមផលល្មមដែរ. ម្តាយអាឡាដាំងក៏គ្មានអ្វីនឹងឆ្លើយតបទៀតទេ ។ គាត់គ្រាន់តែពោលថា: "កូនប្រុស ! ចូរកូនធ្វើតាមគំនិតកូនឯងយល់ចុះ ។ ចំណែកម្តាយៗ ឥតត្រូវការទាក់ទងអ្វីជាមួយពួកអារក្សទេ ។ ម្តាយប្រាប់កូនឯងថា. ម្តាយសុំលាងដៃឱ្យជ្រះស្រឡះចេញពីរឿងនេះហើយៗ ម្តាយឈប់និយាយពីរឿងនេះទៀតហើយ" ។

ល្ងាចស្អែកឡើង. ក្រោយពេលបរិភោគបាយល្ងាចរួច. ម្ហូបចំណីទាំងប៉ុន្មានដែលអារក្សយកមកអស់រលីងគ្មានសល់ ។ ថ្ងៃបន្ទាប់មក.

អាឡាដាំងដែលមិនព្រមនៅស្ងៀម ឱ្យរោគឃ្លានមកញាំញីក្រពះទៀត ក៏ទៅយកចានប្រាក់មួយលាក់ក្រោមអាវរួចចេញពីផ្ទះទៅពីព្រលឹម ដើម្បីយកចាននោះទៅលក់ ។ នៅតាមផ្លូវបុរសក៏បានជួបនឹងមនុស្សកំណាញ់ស្វិតស្វាញម្នាក់ រួចក៏ដឹកដៃជននេះទៅកន្លែងស្ងាត់ពីគេឯង ហើយក៏បង្ហាញចាននេះទៅជននោះដោយសួរថា : "អ្នកត្រូវការទិញចាននេះទេ?" ។

និទានពីជនកំណាញ់នេះវិញ ដែលជាមនុស្សមានល្បិច ហើយចេះដឹងផង, ក៏ទទួលចាននោះមកពិនិត្យមើលស្គាល់ប្រាកដថាចាននេះធ្វើអំពីប្រាក់សុទ្ធមែនទើបសួរទៅអាឡាដាំងថាតើអ្នកលក់ថ្លៃប៉ុន្មាន? ។ អាឡាដាំងដោយពុំបានស្គាល់តម្លៃចាននោះ ហើយដោយពុំធ្លាប់ធ្វើជំនួញរបស់ដូច្នេះផង ក៏និយាយឡើងថា រឿងនេះស្រេចនឹងលោកឱ្យខ្ញុំប៉ុន្មានក៏ឱ្យចុះ ព្រោះលោកស្គាល់តម្លៃរបស់នេះស្រាប់ ។ ជនកំណាញ់ក៏នឹកឆ្ងល់នឹងសេចក្ដីទៀងត្រង់អាឡាដាំងនេះណាស់ ក៏កើតសេចក្ដីមន្ទិលសង្ស័យថា តើអាឡាដាំងស្គាល់តម្លៃនឹងស្គាល់របស់នេះធ្វើពីអ្វីទេ រួចក៏លូកយកប្រាក់មាសមួយដុំពីក្នុងថង់ ដែលមានតម្លៃប្រហែលគ្នានឹងភាគ១/៧២នៃតម្លៃចាននោះ ហុចទៅឱ្យអាឡាដាំងៗ ក៏ទទួលយកលុយនោះយ៉ាងរហ័សរួចដើរចេញទៅ ។ និយាយពីជនកំណាញ់គាត់ឥតមានសប្បាយចិត្តបន្តិចសោះឡើយ ។ ដោយនឹកស្ដាយថាទិញរបស់នេះថ្លៃជ្រុល ព្រោះពុំដឹងជាមុនថាអាឡាដាំងឥតដឹងតម្លៃរបស់



នេះសោះ បើសិនជាគាត់បានដឹងជាមុន, នោះគាត់មុខជាបន្ថោកថ្លៃជាងនេះទៅទៀត ។ គិតដូច្នេះហើយ គាត់ក៏រៀបតែនឹងរត់ទៅតាមអាឡាដាំងភ្លាម ដើម្បីនឹងរកស្ទៀតបោកយកអ្វីពីអាឡាដាំងឱ្យបានខ្លះទៀត ប៉ុន្តែពេលនោះ អាឡាដាំងកំពុងតែដាក់មេផាយយ៉ាងលឿន ជនកំណាញ់ក៏ពុំអាចនឹងរត់ទៅតាមឱ្យទាន់ឡើយ ។

អាឡាដាំងមុននឹងសំដៅចូលទៅផ្ទះវិញ ក៏ឈប់ចូលទៅក្នុងផ្ទះលក់នំប៉ុងមួយ ទិញនំប៉ុងសម្រាប់ម្ដាយនឹងខ្លួនឯងអាស្រ័យ ។ លុះបាននំប៉ុងហើយ អ្នកកំលោះក៏ហុចប្រាក់មាសនោះ ទៅឱ្យម្ចាស់ហាងឱ្យគេថែមលុយមកវិញ ។ លុយដែលសល់បុរសក៏យកទៅជូនម្ដាយដេម្បីទៅផ្សារទិញគ្រឿងបរិភោគសម្រាប់ចិញ្ចឹមជីវិត ក្នុងពេលពីរបីថ្ងៃទៅមុខទៀត ។

ម្ដាយនិងកូនក៏រស់នៅដោយការសន្សំសំចៃដូច្នេះរៀងទៅ គឺថា តែកាលណាថវិកាគ្រួសារអស់, អាឡាដាំងក៏យកចានទៅលក់ឱ្យជនកំណាញ់មួយម្ដងៗ លុះត្រាតែដល់គ្រប់ពីរដណ្ដប់ ។ ឯរបៀបលក់មិនខុសគ្នាពីលើកទីមួយឡើយ ។ ជនកំណាញ់ដោយបានទិញចាននេះពីមុនថ្លៃ ១ដុំមាស ក្រោយមកក៏នៅតែទិញថ្លៃដដែល មិនហ៊ានបន្ថយឱ្យខុសពីមុនទេ ព្រោះខ្លាចខាតមហាលាភគាត់ ។ លុះលុយដែលបានមកពីលក់ចានលើកក្រោយបំផុតចាយអស់ទៅ បុរសរំពឹងឃើញទៅដល់ថាសដាក់ចានទៀតដែលមានទម្ងន់ធ្ងន់១០ដង ច្រើនជាងចាន

មួយៗ។ បុរសចង់យកទៅលក់ឱ្យអ្នកជំនួញដទៃទៀត ប៉ុន្តែវត្ថុនោះមានទម្ងន់ធ្ងន់ពេក អ្នកកំឡោះមិនអាចយកទៅបានឡើយ ត្រូវតែរកហៅជនកំណាញ់មកមើលដល់ផ្ទះ ។ ជនកំណាញ់, ក្រោយដែលបានថ្លឹងមើលទម្ងន់វត្ថុនោះហើយ ក៏រាប់លុយមាស ១០ដុំឱ្យទៅអាឡាដាំងមួយរំពេច។ អាឡាដាំងក៏មានសេចក្តីត្រេកអរជាពន្លឹក ។ លុយ ១០ដុំនេះ អាឡាដាំងដែលធ្លាប់តែដើរលេងប៉ោឡែ ក៏ឈប់ទៅលេងសប្បាយជាមួយនឹងក្មេងឯទៀតហើយ គឺឈប់តាំងពីថ្ងៃដែលបានដើរផ្សងព្រេងជាមួយមេធ្មប់អាហ្វ្រិកាំងមក ។ យុវជនត្រឡប់ជាយកឱកាសដើរលេងឬពិភាក្សាជាមួយជនស្គាល់ៗគ្នាខ្លះ។ ជួនកាលក៏ចូលទៅក្នុងហាងធំៗ ដើម្បីលបស្តាប់ជនអ្នកមុខអ្នកការដែលឈប់ ឬមកប្រជុំគ្នានៅទីនោះ ពិភាក្សាគ្នាអំពីការផ្សេងៗ ។ ការពិភាក្សានៃជនផ្សេងៗនេះយូរៗទៅ បានបំភ្លឺយុវជនឱ្យស្គាល់កិច្ចការនិងដំណឹងសាកលលោកខ្លះៗ ។

លុះចាយលុយមាស ១០ដុំនោះអស់ទៅទៀត អាឡាដាំងក៏រំពឹងឃើញដល់ចង្កៀងទៀត យុវជនចាប់យកវត្ថុនោះមកកាន់នឹងដៃ, បង្វិលរកមើលកន្លែងដែលម្តាយដុសពីមុន។ លុះរកកន្លែងឃើញហើយ បុរសក៏យកដីខ្សាច់មកដុសដូចស្ត្រីមេម៉ាយបានធ្វើពីមុនដែរ ។ មួយរំពេចនោះ, ស្រាប់តែលេចអារក្សដដែល មកនៅពីមុខកូនខ្មោចមុស្តាហ្វាទៀត ។ ប៉ុន្តែដោយអាឡាដាំង ដុសចង្កៀងនេះស្រាលដៃជាង



ម្តាយខ្លួន, អារក្សក៏និយាយសម្តីតិចជាងដែរ ហើយមានសួរស័ព្ទតែមួយដូចមុន “តើលោកត្រូវការអ្វី? ខ្ញុំបាទមកនេះក្នុងឋានៈជាទាសីដើម្បីទទួលបង្គាប់ពីលោក និងអំពីជនទាំងឡាយណា ដែលមានចង្កៀងនេះនៅនឹងដៃ។ មិនតែប៉ុណ្ណោះ នៅមានអារក្សច្រើនទៀតដែលមានភារៈដូចខ្ញុំបាទនេះដែរ” ។

អាឡាដាំងក៏ឆ្លើយតបទៅវិញថា : “ខ្ញុំឃ្លាន, ចូរអ្នកយកអ្វីមកឱ្យខ្ញុំទទួលទាន” ថាតែប៉ុណ្ណេះអារក្សក៏បាត់ខ្លួនទៅ។ បន្តិចមក ក៏ឃើញវាលើកគ្រឿងម្ហូបអាហារមកដូចគ្នានឹងលើកទីមួយដែរ ។វាដាក់របស់នោះលើកៅអីវែងមួយភ្លាម, រួចក៏រំលាយខ្លួនបាត់ទៅ។

ម្តាយអាឡាដាំងបានជ្រាបបំណងកូនគាត់, ក៏ចេញទៅក្រៅផ្ទះយ៉ាងប្រញាប់ ដើម្បីកុំឱ្យជួបមុខនឹងអារក្សនៅក្នុងផ្ទះគាត់ទៀត។ បន្តិចមក គាត់ចូលមកវិញ មានសេចក្តីឆ្ងល់ជាពន់ពេកនឹងផលដ៏អស្ចារ្យដែលកើតពីចង្កៀងនេះ ដោយគាត់ឃើញតុនិងទូដាក់ចាន ប្រដាប់ពាសពេញទៅដោយម្ហូបអាហារ ។ អាឡាដាំងនិងម្តាយក៏បបួលគ្នាអាស្រ័យម្ហូបអាហារចំណីទាំងនោះទៅ។ អាស្រ័យរួចហើយ មាននៅសល់គ្រឿងបរិភោគសម្រាប់បរិភោគពីរថ្ងៃទៅមុខទៀតយ៉ាងបរិបូណ៌។

លុះក្រោយមក, អាឡាដាំងកាលបើឃើញថា នំប៉ុង-ម្ហូបចំណី-លុយកាក់ក្នុងផ្ទះអស់រលីងហើយ ក៏យកចានប្រាក់មកដើរទៅរកជនកំណាញ់ ដើម្បីលក់ចាននោះឱ្យទៀត ។ ក្នុងពេលទៅនោះ

អាឡាដាំងបានដើរកាត់តាមមុខហាងជាងមាសម្នាក់ ដែលមានឫកពាសុភាពតាមជរាវ័យ, ជាមនុស្សស្លូតត្រង់ ថែមទាំងមានភក្តីភាពចំពោះការងារផង ។ ជាងមាស កាលឃើញអាឡាដាំងភ្លាម ក៏ស្រែកហៅឱ្យចូលផ្ទះ រួចគាត់សួរថា: "នែ៎នាង! អ៊ំបានឃើញឯងដើរទៅមកតាមផ្លូវនេះ ដើម្បីទៅផ្ទះជនកំណាញ់ជាច្រើនដងហើយ ដោយមានកាន់អ្វីមួយនៅដៃផង, តែដល់ឯងត្រឡប់មកវិញ អ៊ំឃើញឯងមកតែខ្លួនទទេ, ប្រហែលជាក្មួយឯងយករបស់នោះទៅលក់ឱ្យគេហើយមើលទៅ ។ ក្មួយឯងឥតដឹងថា ជនកំណាញ់នេះជាអ្នកបោកប្រាស់មួយយ៉ាងឆ្នើមបំផុតទេ ។ មនុស្សដែលគេស្គាល់ជននេះច្បាស់ គេស្អប់ខ្ពើមមិនជ្រលក់មាត់ជាមួយវាឡើយ ។ ដែល អ៊ំនិយាយនេះ គឺមានបំណងធ្វើឱ្យក្មួយឯងសប្បាយចិត្ត ។ ហេតុនេះ បើសិនជាក្មួយឯងអាចបង្ហាញឱ្យអ៊ំឃើញរបស់ដែលឯងកាន់អម្បាញ់មិញនេះ ហើយបើត្រូវការលក់ អ៊ំក៏គិតថ្លៃឱ្យយុត្តិធម៌ត្រឹមត្រូវតាមតម្លៃរបស់នោះដែរ នេះបើសិនជាត្រូវចិត្តអ៊ំ ។ បើពុំនោះទេ អ៊ំនឹងប្រាប់ក្មួយឯងឱ្យយកទៅលក់ឱ្យអ្នកជំនួញផ្សេងទៀត ដែលគេមិនចេះបោកប្រាស់អ្នកណានោះ" ។

ឮវាចាដ៏ផ្អែមល្ហែមពីរោះនេះកាលណា អាឡាដាំង ក៏លូកយកចានពីក្នុងអាវមកបង្ហាញជាងមាសភ្លាម ។

ជរាជន លុះបានឃើញចាននោះធ្វើអំពីប្រាក់យ៉ាងសុទ្ធ ក៏សួរទៅអាឡាដាំងថា: ចានដែលក្មួយលក់ឱ្យជនកំណាញ់នោះ មានសណ្ឋានដូច្នេះទាំងអស់ឬ? ។ ហើយតើជននោះឱ្យថ្លៃអ្នកប៉ុន្មាន? អាឡាដាំងក៏



ឆ្លើយដោយត្រង់ថា: បានលក់ឱ្យគាត់អស់ចាន ១២ហើយ។ ចានមួយ។ ថ្លៃ១ដុំមាស ។ ជាងមាសក៏ស្រែកឡើងថា អា! អាមេចោរ ណ្ហើយកូនប្រុស ! ការណាដែលបានជាធ្វើហួសទៅហើយ គឺវាហើយទៅចុះ ពុំបាច់ គិតទៀតទេ ប៉ុន្តែចាំ អ៊ំធ្វើឱ្យឯងស្គាល់តម្លៃចានរបស់ឯងនេះ ដែលធ្វើអំពីប្រាក់យ៉ាងល្អដូចមាននៅក្នុងហាងអ៊ំ នោះឯងនឹងដឹងច្បាស់ថា តើជនកំណាញ់នោះបន្លំឯងអស់ប៉ុន្មានហើយ ។

ថាដូច្នោះហើយ ជាងមាសក៏យកជញ្ជីងមកថ្លឹងចាននោះ ។ រួចក្រោយដែលបាននិយាយពន្យល់អាឡាដាំង អំពីរបៀបលក់ប្រាក់នោះគេគិតយ៉ាងណា គាត់ក៏ពោលថា តាមទម្ងន់ចាននេះ។ ត្រូវតម្លៃប្រហែលនឹងមាស ៧២ដុំ ។ ជាងមាសមិនមែននិយាយតែមាត់ទទេទេ គឺគាត់រាប់លុយឱ្យអាឡាដាំងនៅពេលនោះមួយរំពេច គ្រាន់តែបញ្ជាក់ថែមបន្តិចថា: "ប៉ុណ្ណេះទើបត្រូវតម្លៃរបស់នេះ" ហើយបើសិនជាក្មួយឯងមិនជឿ ឯងអាចទៅសួរពួកជាងមាសដូចយើង គេនឹងប្រាប់អ្នកដោយរីករាយ ។ ហើយបើគេថារបស់នេះ មានថ្លៃច្រើនជាងនេះទៅទៀត អ៊ំសន្យាថានឹងថែមថ្លៃឱ្យឯងទ្វេមួយជាពីរ ។ អ៊ំបានចំណេញតែពីថ្លៃឈ្នួលធ្វើប្រាក់ ដែលទិញពីគេនោះប៉ុណ្ណេះទេ ។ ប៉ុន្តែពួកជនកំណាញ់ដែលមានធមិសច្ចៈ ក៏គេមិនព្រមធ្វើដូចជាអាជនកំណាញ់នេះឡើយដែរ ។

អាឡាដាំងក៏ថ្លែងអំណរគុណដ៏ជ្រាលជ្រៅ ចំពោះជាងមាស

ដែលបានបំភ្លឺខ្លួនដូច្នេះ។ ហើយគ្រាន់តែប៉ុណ្ណេះក៏ខ្លួនបានទទួលលុយយ៉ាងច្រើនទៅហើយ ។ ថ្ងៃក្រោយមក ដើម្បីនឹងលក់ចានឯទៀតនឹងថាសបុរសតែងតែយកមកលក់ឱ្យជាងមាសនេះជានិច្ច ហើយបានទទួលតម្លៃពិតប្រាកដតាមទម្ងន់របស់នោះ ។ អាឡាដាំងនិងម្ដាយ ពិតមែនតែមានទ្រព្យចាយមិនចេះអស់ដូច្នេះ ដោយសារអានិសង្សចង្កៀង ក៏នៅតែបន្តការរស់នៅដោយត្បិតត្បៀតដូចពីមុនដដែល ។ ធ្វើដូច្នេះដើម្បីនឹងឱ្យបានរបស់ប្រើប្រាស់គ្រប់គ្រាន់ នៅក្នុងគេហស្ថានតូចមួយនេះសិន ។ ចំណែកឯម្ដាយអាឡាដាំង គាត់ចំណាយលុយទិញសំលៀកបំពាក់តែលុយដែលគាត់រកបានមក អំពីអំបោះដែលគាត់រវៃរាល់ថ្ងៃ។ អាស្រ័យការរស់នោះដោយល្មមសមគួរនេះ, យើងអាចវិនិច្ឆ័យយ៉ាងរីករាយថា លុយដែលបានមកពីលក់ចាន ១២នេះ, ធ្វើឱ្យជនទាំងពីររស់នៅសប្បាយអស់ពេលពុំតិចឡើយ ។ គឺដោយសារគុណបុណ្យនៃចង្កៀងនេះផង, ទើបស្រីម្ដាយនឹងកូនរស់នៅក្នុងឋានៈ នេះអស់វេលាជាច្រើនឆ្នាំបាន ។

ក្នុងរយៈកាលនេះ អាឡាដាំងតែងតែព្យាយាមទៅជួបអ្នកមុខអ្នកការទាំងឡាយ នៅក្នុងហាងលក់សំពត់ប៉ាក់ឌិន, សូត្រ, ព្រៃនៃមហាពាណិជនៅក្នុងផ្ទះជាងទង ។ នៅក្នុងពេលទៅជួបគេនេះ បុរសក៏បានជជែកលេងជាមួយនឹងគេខ្លះៗដែរ រួចក៏បានជ្រាបដំណឹងសព្វគ្រប់នៅក្នុងលោកនេះ ។ ពិសេសគឺការបានចូលទៅក្នុងផ្ទះជាងទង, បុរសបានភ្ញាក់ព្រើតនឹងសេចក្ដីភន្តច្រឡំដែលយល់ខុសថា ផ្លែឈើ



ដែលខ្លួនបានបេះនៅក្នុងសួន នៅពេលចូលទៅយកចង្កៀងមិនមែនថ្មពណ៌ (ថ្មកែវ) ទេ, គឺជាថ្មមានតម្លៃក្រៃលែងមហិមា ។ ដោយការខំសង្កេតមើលជាងទងលក់នឹងទិញមាសប្រាក់ក្នុងផ្ទះ អាឡាដាំងក៏ស្គាល់របស់និងតម្លៃរបស់ដែលខ្លួនមាននោះយ៉ាងច្បាស់លាស់ ។ ថ្មមានតម្លៃទាំងប៉ុន្មាននៅក្នុងផ្ទះជាងទង ទោះល្អក្ដី ធំក្ដីក៏រកប្រដូចនឹងថ្មមានដំឡៃរបស់ខ្លួនពុំបានឡើយ ។ ពេលនោះអាឡាដាំងក៏យល់ថាផ្ទះខ្លួននឹងក្លាយទៅជាឃ្លាំងមួយមានតម្លៃរកអ្វីប្រដូចគ្មាន។ ដុំថ្មដែលខ្លួនយល់ថា ជារបស់ឥតតម្លៃនោះ គឺមិនមែនសោះ ។ តាំងពីពេលនោះមក អាឡាដាំងខំលាក់ការសម្ងាត់ នេះឥតប្រាប់នរណាម្នាក់ដឹងឡើយ សូម្បីតែម្ដាយខ្លួនក៏ឥតប្រាប់ឱ្យដឹងផងដែរ ។

ប៉ុន្តែយើងកុំបាច់សង្ស័យអ្វីឡើយ ការដែលអាឡាដាំងនៅស្ងៀមនេះ គឺមិនមែនឥតប្រយោជន៍ទេ ។ តទៅមុខ យើងនឹងបានឃើញថា តើអាឡាដាំងឡើងឋានៈទៅដល់កម្ពស់ណា នោះពុំខានទេ។

ថ្ងៃមួយ, ដើរលេងនៅតាមសង្កាត់ក្នុងរាជធានី អាឡាដាំងបានឮសេចក្ដីឃោសនាផ្សាយព្រះរាជសាសន៍ព្រះបាទស៊ុលតង់ បង្គាប់ឱ្យបិទទ្វារហាងទ្វារផ្ទះទាំងឡាយ ហើយត្រូវពួនសម្ងំនៅក្នុងផ្ទះ លុះត្រាតែព្រះអង្គម្ចាស់ បាឌ្រូលប៊ូឌួ[១] (Badroul-boudour) ព្រះរាជបុត្រីព្រះបាទស៊ុលតង់យាងផុតទៅទីស្រង់ទឹក រួចត្រឡប់ចូលទៅព្រះបរមរាជវាំងវិញសិនទើបចេញបាន ។

(១) Badroul-boudour = ព្រះចន្ទពេញបូរមីនៃព្រះចន្ទពេញបូរមី

ដំណឹងសាធារណ៍នេះ, ធ្វើឱ្យអាឡាដាំងចង់មើលព្រះអង្គម្ចាស់ផ្ទាល់ជាពន់ពេកណាស់ ។ ប៉ុន្តែវាគ្មានកន្លែងឯណាក្រៅពីចូលទៅនៅក្នុងផ្ទះដែលខ្លួនស្គាល់ រួចអើតមើលតាមបង្អួចឡើយ ។ ធ្វើដូច្នេះក៏វានៅតែមើលមិនឃើញទៀត ព្រោះជាទំនៀមព្រះអង្គម្ចាស់, តែកាលណាយាងទៅស្រង់ទឹក តែងបាំងព្រះភក្ត្រនឹងកំណាត់ស្តើងជានិច្ច ។ ដើម្បីបំពេញចំណង់ខ្លួន, អាឡាដាំងក៏រកឃើញមធ្យោបាយមួយ ដែលអាចសម្រេចការនេះបាន គឺត្រូវទៅពួននៅក្រោយទ្វារបន្ទប់ទឹកហើយធ្វើយ៉ាងណាឱ្យតែឃើញព្រះអង្គម្ចាស់ចំពីមុខ ។

មួយសន្ទុះក្រោយមក, ព្រះអង្គម្ចាស់ក៏យាងមកដល់ យុវជនក៏ខំផ្ទៀងមើលតាមបណ្តោយប្រហោងទ្វារធំល្មម ដើម្បីកុំឱ្យព្រះអង្គម្ចាស់មើលខ្លួនឃើញវិញ។ មានអស់អ្នក-អស់នាងនិងមនុស្សកម្រេវជាច្រើនដើរហែហមសងខាងនិងពីក្រោយព្រះនាង ។ លុះនៅតែបីឬបួនជំហានទៀតដល់មាត់ទ្វារ ព្រះអង្គម្ចាស់ក៏បើកស្បៃគ្របព្រះភក្ត្រចេញដែលធ្វើឱ្យព្រះនាងទ្រង់អផ្សុកជាពន់ពេក ជាឱកាសឱ្យអាឡាដាំងបានឃើញព្រះភក្ត្រយ៉ាងច្បាស់តាមបំណង ។

ឱ ! ហេតុតែអាឡាដាំងតាំងពីកើតឡើង រហូតមកដល់អាយុប៉ុណ្ណេះ ពុំដែលឃើញមុខស្ត្រីណាផ្ទាល់ដោយឥតបាំងស្បៃ ក្រៅពីមុខម្តាយខ្លួន ដែលមានវ័យចាស់ គ្មានទឹកមុខត្រង់ណាស្រស់ដែលគួរឱ្យបុរសយល់ថាស្ត្រីឯទៀតមានទឹកមុខនិងសម្ផស្សល្អជាងម្តាយខ្លួនឡើយ។ ទើបតែនឹងពេលនេះ បុរសបានដឹងថា មាននារីឯទៀតមានរូបឆោម



លោមពណ៌ល្អឆើតឆាយក្រៃលែងណាស់ ។ ប៉ុន្តែតាមធម្មតាសម្តី ដែលអ្នកផងតែងពោលសរសើរអំពីរូបសម្បត្តិស្ត្រីនោះ ក៏ពុំដែលបានធ្វើឱ្យយើងចាប់អារម្មណ៍ ដូចជាយើងឃើញរូបសម្បត្តិស្ត្រីផ្ទាល់នោះទេ ។

ដូច្នេះហើយ, កាលបើយុវជនបានឃើញរូបព្រះអង្គម្ចាស់ក្សត្រីបាឌ្រូលប៊ូឌួររួចហើយ, ក៏បោះបង់គំនិតដែលយល់ថា ស្ត្រីទាំងអស់សុទ្ធតែមានលម្អប្រហែល១ នឹងម្តាយខ្លួន ។ សង្គ្រាមមនោសញ្ចេតនាក៏កើតមានជាខ្លាំង ប៉ុន្តែបេះដូងអ្នកកំលោះមិនអាចដកចេញពីការទោរទន់ទៅរកវត្ថុ មានជីវិតមួយដែលទើបនឹងធ្វើឱ្យខ្លួនសប្បាយចិត្តស្ទើរឆ្កួតបានឡើយ ។ លម្អព្រះអង្គម្ចាស់ក្សត្រីប្រៀបបានទៅនឹងរស្មីសូរ្យ-សែង នៃព្រះអាទិត្យជិតអស្តង្គត ដែលគេពុំអាចបានឃើញគ្រប់គ្នានៅក្នុងលោកនេះ។ ព្រះនាងមានព្រះចក្ខុធំ១ វៃវៀងហើយភ្លឺថ្លា មានព្រះនាសាសៃនសក្តិសម, មានព្រះឱស្ឋតូចល្មម, ប្រកបដោយរីមក្រហមរលោងពីធម្មជាតិ ហើយសមសួននឹងវង់ព្រះភក្ត្រទាំងអស់គ្មានកន្លែងណាគួរឱ្យទើសទាស់ទំនាស់ដល់ភ្នែកបានឡើយ ។ ពោលដោយខ្លីទៅគឺថាសម្ផស្សភក្ត្រព្រះនាង ល្អគ្មានខ្ចោះត្រង់កន្លែងណាទេ ។ ដូច្នេះគេពុំបាច់សង្ស័យឡើយថា នៅពេលដែលអាឡាដាំងឃើញព្រះនាងភ្លាមអាឡាដាំងភ្លឹកខ្លួនភាំងបាត់ស្មារតីរកនឹកអ្វីពុំឃើញ ។ នេះហើយឬដែលអ្នកប្រាជ្ញខ្លះពោលថា លម្អរបស់ស្ត្រីជាអាវុធមួយយ៉ាងខ្លាំងពូកែបំផុត? ។ រៀបរាប់មកប៉ុណ្ណេះក៏ពុំទាន់សមនឹងលម្អព្រះនាងដែរ ព្រះនាងនៅមានលម្អមួយយ៉ាងឆើតឆាយទៀត គឺព្រះនាងមានព្រះកាយ

ទន់ភ្លន់ លូតលូន់សមរម្យល្អណាស់ ទាំងកិរិយាមារយាទ ទាំងឫកពា គឺថា ជនណាក៏ដោយឱ្យតែបានឃើញព្រះនាងហើយ តែងតែមានចិត្តកោតគោរពជានិច្ច ។

លុះព្រះនាងបានយាងចូលផុត ទៅក្នុងបន្ទប់ទឹកហើយ អាឡាដាំងក៏នៅតែភ្លឹកនៅឡើយ ហាក់ដូចបាត់វិញ្ញាណអស់មួយសន្ទុះ ដោយសារតែកើតមានសតិអារម្មណ៍ផ្សេងៗ ។ ក្រោយដែលបានឃើញរូបសម្ផស្សម្ចាស់ក្សត្រីមក សេចក្ដីស្នេហាក៏បានចូលទៅញាំញីបេះដូងបុរសជាខ្លាំងពន់ប្រមាណ ។ មួយសន្ទុះមក ទើបបុរសបានភ្ញាក់ស្មារតីដឹងខ្លួនដូចដើមវិញ ។ តមកដោយនឹកស្មានថា ម្ចាស់ក្សត្រីយាងចូលទៅក្នុងបាត់ហើយ បើទុកណាជានៅរង់ចាំមើលទៀតក៏ឥតប្រយោជន៍ដែរ, ព្រោះថាដល់ពេលព្រះនាងយាងចេញ ព្រះនាងមុខជាត្រូវបែរខ្នងមករកខ្លួនហើយ ។ គិតដូច្នោះហើយ អាឡាដាំងក៏ថយចេញទៅដោយនឹកស្ដាយកន្លែងនោះរកអ្វីមកប្រៀបពុំបាន ព្រោះគេយល់ថាភ្នែកគេបានឃើញឋានសួគ៌ពិតប្រាកដ ។

ត្រឡប់ទៅផ្ទះវិញ អាឡាដាំងពុំអាចបំភ្លេចនូវសេចក្ដីតប់ប្រមល់ខ្វល់ចិត្តនេះបានឡើយ ។ លុះគ្រាតែម្ដាយឃើញហើយ ឆ្ងល់នឹងការស្រងូតស្រងាត់រវើរវាយប្លែកពីធម្មតា រួចក៏សួរទៅកូនថាតើមានរឿងហេតុអ្វី ឬពុំស្រួលខ្លួន ។ ប៉ុន្តែអាឡាដាំងឥតឆ្លើយតបនឹងសំនួរម្ដាយឡើយ, បែរជាដើរទៅអង្គុយលើកៅអីវែងធ្វើយ៉ាងព្រងើយ ខួរក្បាលអ្នកកំពុងវិលវល់អំពល់គិតតែទៅដល់រូបសម្រស់ឆើតឆាយនៃ



ព្រះនាងបាឌ្រូលប៊ូឌូរតែមួយប៉ុណ្ណេះ ។ នាងមេម៉ាយដែលកំពុងតែចំអិនអាហារ ក៏ឈប់បង្អង់លែងប្រញាប់ដូចមុន ។ លុះដោះម្ហូបអាហារនោះរួច ហើយគាត់ក៏លើកយកមកលើគ្រែវែង ជិតអាឡាដាំង, រួចគាត់ក៏អង្គុយទទួលទាន ។ ប៉ុន្តែដោយគាត់ឃើញកូនគ្មានរវល់អើពើនឹងបាយទឹកសោះ, គាត់ក៏ស្រែកហៅឱ្យចូលមកបរិភោគបាយ ។ បុរសក៏ចូលមកបរិភោគបាយជាមួយម្ដាយ ប៉ុន្តែស្ទើរតែឥតផ្លាស់ប្ដូរទឹកមុខឡើយ ។ ល្ងាចនោះ អ្នកកំលោះអាស្រ័យអាហារតែបន្តិចបន្តួច, ភ្នែកបាញ់ចុះក្រោម, គ្មានមាត់កអ្វីបន្តិចសោះ ។ ចាញ់ចំណេះភរិយាលោកមុស្តាហ្វាមិនដឹងធ្វើដូចម្ដេចឱ្យកូនឆ្លើយនឹងសំនួរគាត់បាន ដើម្បីឱ្យដឹងដើមហេតុអំពីការដែលផ្លាស់ប្ដូរចិត្តគំនិតនេះ ។

លុះអាស្រ័យបាយរួច, ម្ដាយអាឡាដាំងក៏ចង់សាកសួរកូនគាត់សាជាថ្មីម្ដងទៀត ប៉ុន្តែឥតបានការអ្វីសោះ, បុរសក៏ចូលទៅគេងបាត់ទៅ ឥតនៅឱ្យម្ដាយបានសួរពីរឿងនេះខ្លះទៀតឡើយ ។

រាត្រីក៏កន្លងទៅ,គេឥតទាន់បានដឹងរឿងរ៉ាវអាឡាដាំងយ៉ាងដូចម្ដេចទេ វាកំពុងឈ្លក់ចិត្តនឹងសម្រស់រូបសម្បត្តិព្រះនាងបាឌ្រូល-ប៊ូឌូរណាស់ ។ ប៉ុន្តែស្អែកឡើង, យើងសម្គាល់ឃើញអាឡាដាំងអង្គុយលើកៅអីវែងទល់មុខម្ដាយ ដែលកំពុងរវើកប្បាសរួចពោលថា "អ្នកម្ដាយ ! ខ្ញុំសុំពោលលាតត្រដាងជម្រាបអ្នកម្ដាយ អំពីការសម្ងាត់ដែលខ្ញុំបានលាក់ទុកតាំងពីម្សិល នៅពេលដែលខ្ញុំត្រឡប់មកពីទីក្រុងវិញ ។

ការណ៍នេះខ្ញុំបានយល់ច្បាស់ថា នឹងធ្វើឱ្យអ្នកម្ដាយព្រួយចិត្ត ។ ឥឡូវខ្ញុំជម្រាបថា ខ្ញុំឥតមានឈឺចាប់អ្វីដូចអ្នកម្ដាយស្មាននោះទេ ទាំងពេលឥឡូវនេះសោត ក៏ឥតមានឈឺអ្វីដែរ ។ ប៉ុន្តែខ្ញុំដូចជារកជម្រាបពុំបានសោះអំពីរឿងខ្ញុំ ។ រឿងនេះគឺមានពិសពុលជាងជំងឺមែនៗ ទៅទៀត តែខ្ញុំពុំដឹងថា តើខ្ញុំឈឺអ្វី ។ ណ្ហើយចុះ ទោះបីយ៉ាងណាក៏ដោយ ក៏ខ្ញុំឥតសង្ស័យដែរថា រឿងដែលខ្ញុំប្រុងនឹងជម្រាបនេះ នឹងធ្វើឱ្យអ្នកម្ដាយយល់ពុំខាន។ ដូច្នេះអាឡាដាំងក៏ពោលទៅទៀតថា: នៅក្នុងសង្កាត់នេះ ឥតនរណាមួយបានដឹងថាពីម្សិលមិញនេះពេលបាយព្រលឹមរួចព្រះអង្គម្ចាស់បាឌ្រូលប៊ូលឌួរ ព្រះរាជបុត្រីព្រះបាទស៊ុលតង់ស្ដេចយាងទៅក្រសាលឯកន្លែងទឹកទេ ។ ហេតុនេះហើយបានជាអ្នកម្ដាយពុំអាចជ្រាបរឿងនេះបាន ។ ឯចំណែកខ្ញុំៗ បានដឹងរឿងនេះ ដោយខ្ញុំបានដើរទៅលេងឯទីក្រុងឮគេឃោសនា ប្រកាសប្រាប់ពួកអ្នកនគរឱ្យបិទទ្វារហាង, ឱ្យសម្ងំនៅក្នុងផ្ទះ, ដើម្បីជាកិត្តិយសដល់ព្រះនាងផង និងទុកផ្លូវឱ្យព្រះនាងយាងទៅដោយសេរីផង កុំឱ្យមានទើសទាស់អ្វីដល់ការចរាចរ។ ពេលនោះ ដោយខ្ញុំចង់ឃើញព្រះរាជបុត្រីពេក, ខ្ញុំក៏ទៅពួនចាំនៅជិតមាត់ទ្វារកន្លែងស្រង់ទឹក។ ដោយនឹកថា ព្រះនាងមុខជាបើកស្បៃព្រះភក្ត្រចេញមិនខាន នៅពេលមុនយាងចូលទៅកន្លែងស្រង់ទឹកនោះ។ អ្នកម្ដាយក៏ដឹងដែរ របៀបគេដាក់ទ្វារបន្ទប់នោះយ៉ាងណា ហើយអាចសន្និដ្ឋានបានថា ខ្ញុំអាចមើលព្រះនាងឃើញយ៉ាងជាក់ណាស់



បើសិនជាការនេះប្រព្រឹត្តទៅដូចជាខ្ញុំស្មានទុកជាមុនមែន។ ពិតដូច្នោះមែន, នៅពេលចូលទៅក្នុងបន្ទប់ ព្រះនាងក៏បកស្បៃមុខចេញ ខ្ញុំក៏បានទទួលសុភមង្គលនឹងមើលព្រះនាងជាទីស្នេហានេះតាមអំពើចិត្តប្រកបដោយសេចក្ដីសោមនស្សយ៉ាងក្រៃលែងផង ។ នេះហើយ អ្នកម្ដាយដែលជាហេតុនៃទុក្ខរបស់ខ្ញុំ និងជារឿងរ៉ាវដែលខ្ញុំនៅស្ងៀមស្រងូតស្រងាត់ អណ្ដែតអណ្ដូង រហូតមកដល់ពេលនេះដូចអ្នកម្ដាយ បានឃើញពីម្សិលមិញស្រាប់ នៅពេលខ្ញុំត្រឡប់មកពីដើរលេងវិញ ។ ខ្ញុំមានសេចក្ដីស្នេហាទៅលើរូបព្រះនាងនោះ ជាពន់ពេកណាស់ តែពុំអាចនឹង ជម្រាបអ្នកម្ដាយបានឡើយ ។ តណ្ហាដ៏ក្លៀវក្លាម៉ុះមុតរបស់ខ្ញុំកើតមានឡើងគ្រប់វេលា ។ ខ្ញុំយល់ច្បាស់ថា ដើម្បីធ្វើឱ្យតណ្ហានេះសុខចិត្ត លុះត្រាតែបានព្រះនាងម្ចាស់ក្សត្រីបាឌ្រូលប៊ូឌួរនេះមកជាសម្បត្តិប្រចាំជីវិតរបស់ខ្ញុំ ។ ពោលឱ្យចំទៅ គឺថាខ្ញុំបានសម្រេចចិត្តជាស្រេចថានឹង ចូលទៅដណ្ដឹងព្រះនាងពីព្រះបាទស៊ុលតង់រៀបអាពាហ៍-ពិពាហ៍ឱ្យខាងតែបាន ។

ម្ដាយអាឡាដាំង បានអង្គុយស្ដាប់កូននិយាយ លុះត្រាតែចប់សព្វគ្រប់ ហើយក៏យល់បំណងរបស់បុត្រគាត់ គឺចង់ដណ្ដឹងព្រះអង្គម្ចាស់បាឌ្រូលប៊ូឌួរធ្វើជាភរិយា,គាត់ក៏សើចចំអកឱ្យយ៉ាងខ្លាំងកាត់សម្ដីកូន។ អាឡាដាំងរៀបពោលតទៅទៀត ទទួលម្ដាយនិយាយកាត់ទៀតថា : “នែ ! កូនប្រុសម្ដាយ តើកូនគិតអ្វីហ្នឹង?” ។ កូនខូចខួរក្បាលហើយមើលទៅ បានជាចេះតែនិយាយរឿងដូច្នេះប្រាប់ម្ដាយ ! ។

ជម្រាបអ្នកម្ដាយ, អាឡាដាំងពោល ខ្ញុំសូមបញ្ជាក់ប្រាប់អ្នកម្ដាយថា ខ្ញុំឥតខូចខួរក្បាលទេ ។ ខ្ញុំនៅមានសុភវិនិច្ឆ័យពេញលេញ ហើយខ្ញុំបានឮទាំងអស់ ពាក្យនិន្ទាតិះដៀលរបស់ម្ដាយដែលថាខ្ញុំវិកលចរិត និយាយប៉ប៉ាច់ប៉ប៉ោចឥតដឹងខុសត្រូវនិងអំពើផ្សេងទៀត ដែលអ្នកម្ដាយអាចនិន្ទាតិះដៀលខ្ញុំបាន ។ ប៉ុន្តែការទាំងប៉ុន្មាននេះ មិនអាចជាឧបសគ្គស្ទាក់ខ្ញុំកុំឱ្យជម្រាបអ្នកម្ដាយថា សេចក្ដីសម្រេចចិត្តរបស់ខ្ញុំ គឺត្រូវតែដណ្ដឹងព្រះនាងបាឌ្រូលប៊ូឌូរ ព្រះរាជបុត្រីព្រះបាទស៊ុលតង់ធ្វើជាភរិយាឱ្យទាល់តែបានទេ ។

តាមពិត, កូនប្រុសម្ដាយ !, នាងមេម៉ាយមុស្ដាហ្វាឆ្លើយយ៉ាងម៉ឹងម៉ាត់ ម្ដាយពុំដឹងជាហាមឃាត់ឯងកុំឱ្យនឹកម្ដេចកើតទេ ប៉ុន្តែគឺខ្លួនឯងហ្នឹងហើយ ដែលត្រូវបំពេញមុខការនេះឱ្យបានសម្រេច។ ឯម្ដាយ១ពុំដឹងថា តើកូននឹងទៅពឹងពាក់នឹងនរណា ឱ្យគេចូលទៅនិយាយស្ដីការនេះនឹងព្រះបាទស៊ុលតង់ទេ ។ គឺអ្នកម្ដាយឯងហ្នឹងហើយ, អាឡាដាំងឆ្លើយយ៉ាងរហ័សដោយឥតញញើតមាត់ឡើយ, ខ្លួនម៉ែ? នាងស្រីបញ្ចេញសម្លេងព្រមទាំងទឹកមុខភ្ញាក់ផ្អើលហើយឆ្ងល់ផង ។ ចុះព្រះបាទស៊ុលតង់ !...។ អែយ៉ា !... ម្ដាយមិនព្រមចូលទៅលាយឡំក្នុងកិច្ចការដូច្នេះទេ ។ នែកូន ! គាត់បន្ត តើកូនឯងដឹងថាខ្លួនជាអ្វីទេបានជាមានចិត្តធំហ៊ាននឹកចង់បានព្រះរាជបុត្រីព្រះបាទស៊ុលតង់ ដែលជាម្ចាស់ផែនដីអ្នក? ឯងភ្លេចហើយឬនៅថា ឯងនេះជាកូនអ្នកកាត់



ដេរខោអាវ មានភោគសម្បត្តិដ៏ស្ដួចស្ដើង។ ឯម្ដាយទៀតក៏ពុំមែនកើតក្នុងត្រកូលដ៏ខ្ពង់ខ្ពស់ដែរ ។ ឯងដឹងថា ព្រះបាទស៊ុលតង់ សូម្បីតែព្រះរាជបុត្រនៃស៊ុលតង់ទាំងឡាយណា ដែលគ្មានសង្ស័យថានឹងបានសោយរាជ្យដូចព្រះអង្គនោះ ក៏ព្រះអង្គមិនទ្រង់ព្រមឱ្យព្រះរាជបុត្រីព្រះអង្គរៀបអភិសេកជាមួយឡើយ ។ អ្នកម្ដាយ, អាឡាដាំងឆ្លើយ, ខ្ញុំបាននិយាយជម្រាបអ្នកម្ដាយរួចហើយថា រឿងអ្វី១ ដែលអ្នកម្ដាយទើបតែនឹងមានប្រសាសន៍នេះ ខ្ញុំយល់ហើយឮហើយ, ជ្រាបហើយហើយខ្ញុំ សូមជម្រាបដដែលទៀត ឱ្យអ្នកម្ដាយយល់ថា: វាចានឹងពាក្យទូន្មានប្រៀនប្រដៅរបស់អ្នកម្ដាយនេះ មិនបានឱ្យខ្ញុំផ្លាស់ប្ដូរមនោសញ្ចេតនាអ្វីបន្តិចឡើយ ។ ខ្ញុំបានជម្រាបទៀតថា គឺខ្លួនអ្នកម្ដាយនេះហើយដែលចូលទៅធ្វើជាអ្នកផ្លូវចៅមហា ស្ដីដណ្ដឹងព្រះនាងបាឌ្រូលប៊ូឌូររៀបអាពាហ៍ពិពាហ៍ ។ ការដែលកូនធ្វើនេះ គឺកូនសុំទោសអ្នកម្ដាយដោយសេចក្ដីគោរពដែលខ្ញុំត្រូវមានចំពោះអ្នកម្ដាយ តែកូនសុំលន់តួអង្វរថា សូមអ្នកម្ដាយកុំប្រកែកឱ្យសោះ បើចង់ឱ្យកូនរស់តទៅទៀត ជាជាងឃើញកូនស្លាប់នោះ" ។ ម្ដាយអាឡាដាំងទាល់គំនិតល្ងីតល្ងឹងស្ងួនឡ កាលបើឃើញកូនគាត់ប្រកាន់ខ្ជាប់ម៉ឹងម៉ាត់នូវយោបល់ខុសប្រាសចាក ពីសុភវិនិច្ឆ័យស្រឡះ គាត់ក៏បញ្ជាក់ថែមទៀតថា: "កូនប្រុសម្ដាយ ! អញជាម្ដាយកូនឯង ហើយដើម្បីឱ្យបានសមរម្យជាម្ដាយប្រកបដោយធម៌ ដែលបានបង្កើតឯងមកក្នុងលោកនេះ, គ្មានអ្វី

ឱ្យសមហេតុសមផលហើយប្រពៃផង ក្រៅអំពីប្រុងប្រៀបរៀបចំរកគូស្រករឱ្យកូនឯងឡើយ ។ នេះជាព្រហ្មវិហារធម៌នៃម្ដាយត្រូវមានចំពោះកូនតែបើសិនជារឿងរកគូរៀបអាពាហ៍ពិពាហ៍នេះ ត្រូវលើកកូនអ្នកជិតខាងដែលមានឋានៈប្រហែលឯងឬក៏អន់ថយលើសខ្ពះបន្តិចបន្តួចនោះៗ ម្ដាយឥតប្រកែកសោះឡើយ ។ ម្ដាយនឹងខំប្រឹងឱ្យអស់កម្លាំងចិត្តកម្លាំងកាយ ដែលម្ដាយអាចធ្វើបាន ។ ប៉ុណ្ណេះក៏នៅពុំទាន់គ្រប់គ្រាន់ទៀត, ត្រូវឯងមានទ្រព្យសម្បត្តិប្រាក់កាស ឬត្រូវចេះមុខរបរអ្វីមួយផងទៀត ។ ពួកអ្នកខ្សត់ទ្រព្យធនដូចយើង កាលណាគេចង់រៀបការរបស់ទីមួយ ដែលគេត្រូវគិតបំផុតនោះ គឺត្រូវមានលុយកាក់ទ្រព្យសម្បត្តិសម្រាប់ចិញ្ចឹមជីវិត ។ ប៉ុន្តែកូនឯងនេះគ្មានគិតអំពីឋានៈវង្សត្រកូល គ្មានគិតអំពីទ្រព្យសម្បត្តិរបស់ខ្លួនមានសិនសោះ, ក៏តាំងត្រដាងស្លាបចង់ហើរទៅទំលើគំនរទ្រព្យយ៉ាងខ្ពង់ខ្ពស់បំផុតទៅហើយ ។ គឺឯងចង់ស្ដីដណ្ដឹងព្រះរាជបុត្រីម្ចាស់ផែនដី ដើម្បីរៀបអាពាហ៍ពិពាហ៍ជាមួយ ។ ឱកូនអើយ ម្ចាស់ផែនដីបើព្រះអង្គមិនសព្វព្រះទ័យនឹងឯងព្រះអង្គគ្រាន់តែមានព្រះរាជឱង្ការមួយម៉ាត់ប៉ុណ្ណោះ អាចធ្វើឱ្យឯងឈានជើងចុះចេញជាប្រញាប់ ហើយអាចធ្វើឱ្យឯងវិនាសផង ។ ការនេះម្ដាយសូមស្លេះទុកមួយកន្លែងសិន គឺទុកឱ្យឯងពិចារណារកខុសរកត្រូវដោយខ្លួនឯង បន្តិចទៀតអ្នកនឹងមានសុភវិនិច្ឆ័យពុំខាន ។ ពោលមកដល់ត្រង់នេះ ម្ដាយរំភើបចិត្តណាស់ហេតុអ្វីក៏ចិន្តាដ៏ចម្លែកនេះ,



ចិន្តាដែលចង់ឱ្យម្ដាយចូលទៅស្នើការនឹងព្រះបាទស៊ុលតង់ ដើម្បីនឹងសូមទ្រង់អនុញ្ញាតឱ្យព្រះរាជបុត្រីព្រះអង្គរៀបការជាមួយនឹងឯងនោះអាចចូលមកដុះស្នឹមក្នុងខួរក្បាលឯងបាន? ឧបមាថាម្ដាយមានចិត្តក្លាហាន ហ៊ានចូលទៅថ្វាយបង្គំគាល់ព្រះមហាក្សត្រ, ដើម្បីសូមទ្រង់ព្រះរាជានុញ្ញាតក្រាបទូលពីរឿងនេះ តើម្ដាយត្រូវទៅសុំនរណាចូល? ត្រូវឯងជឿថា បុរសដែលម្ដាយនិយាយទៅកាន់ជាដំបូងនោះ មិនចោទម្ដាយថាឆ្កួតទេឬ? ហើយគេនឹងបណ្ដេញម្ដាយចេញដោយពាក្យទ្រគោះបោះបោកសមតាមមារយាទម្ដាយទេ? ម្ដាយឧបមាមួយទៀតឱ្យកូនស្ដាប់ថា: គ្មានឧបសគ្គអ្វីទេ រឿងដែលគ្រាន់តែសុំចូលទៅគាល់ព្រះបាទស៊ុលតង់នោះ តែម្ដាយដឹងថា ដែលគ្មានឧបសគ្គនោះ គឺការដែលចូលទៅគាល់ព្រះមហាក្សត្រ ដើម្បីសុំទ្រង់រកសេចក្ដីយុត្តិធម៌ឱ្យប៉ុណ្ណេះ ។ បើសិនជាចំលើរឿងនេះ ព្រះអង្គទ្រង់រកសេចក្ដីពិតឱ្យបរិវារព្រះអង្គមួយរំពេច ។ មួយទៀត ម្ដាយដឹងថាបើកាលណាគេចូលទៅគាល់ព្រះអង្គ ដើម្បីសុំឱ្យទ្រង់លើកលែងត្រាប្រណីទោសអ្វីមួយ, ព្រះអង្គនឹងទ្រង់លើកលែងទោសឱ្យដោយរីករាយ ។ បើព្រះអង្គឈ្វេងយល់ថា អ្នកនោះគួរអនុញ្ញាតឱ្យបាន អ្នកនោះជាមនុស្សស្លូតត្រង់ទេ ។ ចុះឯង តើឯងមានរឿងដូច្នេះទេ ហើយតើឯងនឹងស្មានថាឯងត្រូវបានទទួលព្រះរាជអនុគ្រោះ ដែលឯងចង់ឱ្យម្ដាយទៅសុំព្រះអង្គឱ្យនោះទេ? តើខ្លួនឯងគួរដល់ហេតុផលនេះទេ? តើឯងបានធ្វើ

ប្រយោជន៍អ្វីខ្លះដល់ម្ចាស់ផែនដី ។ ឯងមាតុភូមិឯងចុះឯងមានគុណសម្បត្តិត្រង់ណាដែលប្រសើរជាងគេនោះ? បើឯងគ្មានបានធ្វើអ្វីដើម្បីនឹងត្រូវបានទទួលសេចក្តីត្រាប្រណីទោសនោះសោះ។ ម្យ៉ាងទៀត. បើឯងមិនមែនជាមនុស្សប្រសើរថ្លៃថ្នូរផង តើឱ្យម្តាយចេញមុខទៅនិយាយស្តីដណ្តឹងព្រះរាជបុត្រីព្រះអង្គម្តេចបាន? តើម្តាយអាចហារមាត់ស្នើការនេះដល់ព្រះបាទស៊ុលតង់ដូចម្តេចកើត? គ្រាន់តែឃើញដំណើរដ៏អង់អាចរបស់ព្រះអង្គនិងសូរស័ព្ទសម្លេងអស់នាម៉ឺនសព្វមុខមន្ត្រីប៉ុណ្ណោះ ធ្វើឱ្យម្តាយបិទមាត់ជិតស្លុងទៅហើយ ម្តាយនឹងញ័រតក់ស្លុតដូចកាល ម្តាយមានការអ្វីបន្តិចបន្តួចទៅសួរខ្មោចឪពុកឯង កាលគាត់នៅរស់ដូច្នេះដែរ ។ នៅមានរឿងមួយទៀត ដែលកូនឯងឥតបានគិតសោះ គឺថាគេមិនដែលចូលទៅគាល់ព្រះមហាក្សត្រ ដោយឥតមានរបស់អ្វីយកទៅថ្វាយនោះឡើយ ។ បើកាលណាគេមានការសុំព្រះរាជានុញ្ញាតរឿងអ្វីមួយ។ ដង្វាយនេះមានប្រយោជន៍ដូច្នេះ បើព្រះអង្គពុំទ្រង់យល់ព្រមអំពីរឿងអ្វី ដោយទ្រង់មានវិចារណញ្ញាណផ្សេងៗនោះក៏ព្រះអង្គ ទ្រង់ព្រះសណ្តាប់នូវសេចក្តីទូលសុំនៃអ្នកចូលទៅគាល់នោះដោយឥតធុញទ្រាន់ដែរ។ ចុះឯងតើមានរបស់អ្វីនឹងយកទៅថ្វាយព្រះអង្គ។ បើកាលណាឯងបានរបស់នោះហើយតែមិនសមនឹងព្រះសម្ភោធិបារមីនៃព្រះមហាក្សត្រ តើព្រះអង្គនឹងទ្រង់មានព្រះចិន្តាដូចម្តេច ចំពោះការស្នើទូលរបស់ឯង? ត្រូវឯងគិតរំពឹងឱ្យមែនទែនចុះថាឯងប្រាថ្នាតែរបស់អ្វីដែលហួសវិស័យឯងធ្វើបាន” ។



អាឡាដាំងបានអង្គុយយ៉ាងស្ងៀមស្ងាត់ ស្តាប់សព្វគ្រប់ទាំងអស់ នូវពាក្យម្តាយទាំងប៉ុន្មាន ដែលខំនិយាយពន្យល់ខ្លួនឱ្យងាកបែរពីគំនិតនេះចេញ ។ បន្ទាប់មកក្រោយដែលបានត្រិះរិះនូវគ្រប់ចំណុចនៃពាក្យទូន្មានម្តាយរួច. បុរសក៏ពោលទៅកាន់ម្តាយថា: “អ្នកម្តាយ ! កូនសូមទទួលសារភាពថា នេះគឺចិត្តព្រើលរបស់ខ្ញុំ ដែលហ៊ានបណ្តោយចិត្តខ្លួនឱ្យជ្រុលហួសការដែលខ្លួនធ្វើ គឺជាការឆ្កាំឆ្គងមួយដែលបានដាក់កំហិតដោយបង្ខំនិងដោយប្រញាប់ ឱ្យអ្នកម្តាយចូលទៅនិយាយស្នើការនឹងព្រះបាទស៊ុលតង់ អំពីរឿងអាពាហ៍ពិពាហ៍នេះ ដោយឥតបានបង្ហាញមធ្យោបាយជម្រាបអ្នកម្តាយឱ្យច្បាស់លាស់ជាមុន ក្នុងការចូលទៅគាល់ព្រះអង្គ ។ កូនសូមអភ័យទោសអ្នកម្តាយ ប៉ុន្តែកម្លាំងតណ្ហារបស់កូនក្នុងពេលនេះ សូមអ្នកម្តាយកុំឆ្ងល់ឱ្យសោះថា គ្មានអ្វីអាចធ្វើឱ្យកូននៅស្ងៀមបានឡើយ ។ កម្លាំងតណ្ហារបស់ខ្ញុំប្រៀបបានទៅនឹងទឹកជ្រោះដែលហូរចុះមកពីកំពូលភ្នំដ៏ខ្ពស់ដូច្នេះឯង គ្មានអ្វីអាចទប់បានឡើយ ។ កូនស្រឡាញ់ព្រះអង្គម្ចាស់បាទ្រូលប៊ូឌូរ ហួសវិស័យនឹងអ្នកម្តាយយល់បាន គឺថាខ្ញុំស្រឡាញ់ស្ទើរលេប ហើយគំនិតខ្ញុំប្រកាន់ខ្ជាប់ថា ត្រូវតែរៀបការជាមួយនឹងព្រះនាង។ គំនិតនេះឋិតនៅជាប់នឹងខួរក្បាលខ្ញុំអស់ប្រែប្រួលទៅណាកើតទៀតហើយ។ ខ្ញុំសូមឱ្យអ្នកម្តាយដើរតាមផ្លូវ ដែលអ្នកម្តាយបានមានប្រសាសន៍ប្រាប់កូនអម្បាញ់មិញនេះចុះ កូនសម្លឹងរំពឹងឃើញថា ផ្លូវនេះជាជំហានទីមួយដែល

អាចផ្ដល់ដល់កូន នូវលទ្ធផលមួយដ៏ប្រសើរដែលកូនសន្យាថានឹងធ្វើបាន។ អ្នកម្ដាយមានប្រសាសន៍ប្រាប់កូនថា ជាទំនៀមមកគេមិនដែលចូលទៅគាល់ស្ដេចដៃទទេនោះទេ។ ម្យ៉ាងទៀតថា កូនគ្មានអ្វីធ្វើជាជង្វាយ ដើម្បីជាការគួរសមដល់ព្រះអង្គឡើយ ។ ចំពោះរឿងជង្វាយ. កូនទទួលសុខចិត្តមែន. ព្រោះកូនឥតបាននឹកនាសោះ ។ តែឯចំណែកដែលថាកូនគ្មានរបស់អ្វីយកទៅថ្វាយនោះ ប្រហែលអ្នកម្ដាយឥតបានជ្រាបទេឬ របស់ដែលខ្ញុំបានមក នៅថ្ងៃដែលខ្ញុំគេចខ្លួនពីមរណភាពដោយសាររបៀបយ៉ាងណាដែលអ្នកម្ដាយបានដឹងស្រាប់, តើរបស់នេះមិនមែនជាជង្វាយដ៏ប្រសើរអាចធ្វើឱ្យព្រះបាទស៊ុលតង់សព្វព្រះទ័យឬ? ខ្ញុំពោលនេះ គឺពោលអំពីរបស់ដែលខ្ញុំបានយកមក ដោយដាក់ក្នុងថង់ពីរនិងក្នុងខ្សែក្រវាត់ជុំវិញចង្កេះ ហើយដែលអ្នកម្ដាយនិងខ្ញុំទាំងពីរនាក់យល់ថាជាកែវពណ៌ផ្សេងៗ ទៅវិញ ។ ប៉ុន្តែឥឡូវនេះ ខ្ញុំលែងយល់ច្រឡំហើយ ខ្ញុំសូមជម្រាបអ្នកម្ដាយថា គឺសុទ្ធតែថ្មកែវដ៏មានតម្លៃលើសលុប ដែលព្រះមហាក្សត្រនៃអាណាចក្រធំៗ ទទើបមាន។ ខ្ញុំស្គាល់គុណូបការរបស់នេះ ដោយសារបានចូលទៅលេងក្នុងហាងជាងទង ។ សូមអ្នកម្ដាយជឿសម្ដីកូនចុះ ថ្មទាំងឡាយឯទៀត ដែលខ្ញុំបានឃើញនៅក្នុងផ្ទះអ្នកលក់មាសប្រាក់ទាំងទំហំ ទាំងលម្អ ឥតមានដូចនឹងថ្មរបស់យើងនេះឡើយ។ ប៉ុន្តែបើទុកជាដូច្នេះក៏ដោយ ក៏អ្នកជំនួញទាំងនោះនៅតែលក់ថ្លៃហួសប្រមាណ ។ តាមពិត អ្នកម្ដាយនិងខ្ញុំពុំ



ទាន់ដឹងតម្លៃវត្ថុរបស់យើងនេះឡើយ ។ ទោះជារបស់នេះមានតម្លៃខុសពីវិនិច្ឆ័យ ដោយការពិសោធដ៏អន់ថយនៃខ្លួនខ្ញុំក៏ដោយ។ ក៏ខ្ញុំជឿជាក់ថា ជង្វាយនេះនឹងអាចពេញព្រះទ័យព្រះបាទស៊ុលតង់ជាក្រៃលែង។ អ្នកម្ដាយមានចានធ្វើអំពីពស៊្វីឡែនមួយធំល្មម ហើយមានរាងរៅសមស្អាតផង ដើម្បីនឹងដាក់របស់នេះ ។ អ្នកម្ដាយយកចាននោះមក រួចក្រោយដែលយើងតម្រៀបថ្មទាំងនេះដាក់ក្នុងចានឆ្លាស់ពណ៌ វាត្រឹម-ត្រូវ. យើងនឹងឃើញតម្លៃដែលលេចចេញមកអំពីរបស់នោះភ្លាម ” ។

ស្រីមេម៉ាយក៏យកចាននោះមក. អាឡាដាំងក៏លូកយកថ្មមានតម្លៃពីក្នុងថង់ទាំងពីរ តម្រៀបដាក់ក្នុងចាននោះ ។ លម្អដែលលេចចេញមកពីថ្មនោះនៅពេលថ្ងៃពេញរស្មី គឺលម្អនិងពណ៌ខុសគ្នា. និងសណ្ឋានខាងក្រៅ. និងលម្អនៃការភ្លឺចាំង ធ្វើឱ្យម្ដាយនិងកូនទាំងពីរនាក់សម្លឹងមើលស្ទើរភ្លឹកបាត់ស្មារតី ។ មិនតែប៉ុណ្ណោះ ជនទាំងពីរនាក់មានសេចក្ដីងឿងឆ្ងល់ភ្ញាក់ផ្អើលជាខ្លាំង ដោយជនទាំងនេះធ្លាប់មើលរបស់នេះតែនឹងពន្លឺចង្កៀង ។ ពិតមែនហើយតែអាឡាដាំងបានឃើញថ្មទាំងនេះ នៅលើដើមឈើផ្សេងៗ មានសភាពហាក់ដូចជាផ្លែឈើគួរដល់ទស្សនិភាពដ៏ប្លែកអស្ចារ្យណាស់. ប៉ុន្តែដោយកុមារមានវ័យខ្ចីនៅឡើយ ក៏យល់ថាថ្មនេះជាគ្រឿងមាសប្រាក់សម្រាប់លេងសប្បាយទៅវិញ ។ បុរសគ្មានរវល់គិតគួរអ្វីក្រៅពីមើលរបស់នោះឡើយ ។

តមក. ក្រោយពីបានឈរសរសើរអំពីលម្អនៃដង្វាយនេះ. បុរសក៏ពោលឡើងថា : “អ្នកម្ដាយ ! អ្នកម្ដាយលែងមានរឿងអ្វីដោះសារប្រកែកមិនព្រមទៅគាល់ព្រះមហាក្សត្រទៀតហើយ ព្រោះមានរបស់យកទៅថ្វាយព្រះអង្គហើយ ។ តាមខ្ញុំស្មានដង្វាយនេះអាចធ្វើឱ្យអ្នកម្ដាយបានទទួលសេចក្ដីរាប់អានដ៏ពេញចិត្តពីព្រះបាទស៊ុលតង់” ។

ម្ដាយអាឡាដាំង ពិតមែនតែគាត់គ្មានយល់ទាស់នឹងដង្វាយនោះទេ ក៏គាត់នៅតែពុំទាន់ជឿថា របស់នេះមានតម្លៃដូចកូនគាត់យល់នោះឡើយ ។ គាត់បែរជាគិតដូច្នេះវិញថា របស់នេះគ្រាន់តែជាគ្រឿងញ៉ាំងព្រះទ័យព្រះអង្គឱ្យទទួលប៉ុណ្ណោះទេ តែដោយគ្មានអ្វីឆ្លើយតបនឹងកូនគាត់វិញ ក៏គាត់នៅស្ងៀមទៅ ។ រឿងនេះធ្វើឱ្យគាត់បារម្ភជាពន់ពេក ទើបគាត់ស្រដីទៅកាន់បុត្រថា : “កូនប្រុសម្ដាយ ! ម្ដាយឥតយល់ទាស់ទេ. ដង្វាយនេះមុខជាផ្ដល់ផលពុំខាន ហើយព្រះបាទស៊ុលតង់មុខជានឹងសព្វព្រះទ័យ នឹងទតមើលម្ដាយដោយពេញព្រះនេត្រ” ។ ប៉ុន្តែដល់ម្ដាយត្រូវនិយាយពីរឿងដែលឯងប្រាថ្នានោះ. ម្ដាយដឹងថា ម្ដាយគ្មានកម្លាំងនឹងថ្លែងសោះ ហើយម្ដាយមុខជាអង្គុយនៅស្ងៀមឥតនិយាយស្ដីឡើយ ។ ដូច្នេះ មិនត្រឹមតែខាតកម្លាំងម្ដាយដើរទេ ថែមទាំងខាតដង្វាយទៀត ដែលតាមកូនឯងស្គាល់គឺជាសម្បត្តិមួយយ៉ាងសម្បើមណាស់ ហើយម្ដាយនឹងត្រឡប់មកវិញដោយសេចក្ដីអៀនខ្មាស នឹងប្រាប់ថាកូនឯងបាត់សេចក្ដីសង្ឃឹមហើយ ។ ម្ដាយបាន



ប្រាប់ឯងរួចហើយ ត្រូវឯងជឿថា រឿងនេះនឹងមានឡើងដូច្នេះជាប្រាកដ ។ ប៉ុន្តែ គាត់បន្ថែមសេចក្ដី. ដើម្បីនឹងទទួលធ្វើតាមឆន្ទៈឯងនេះ. ម្ដាយត្រូវខាំមាត់សង្កត់ចិត្តបន្តិចហើយៗ ត្រូវមានសេចក្ដីក្លាហានដ៏គ្រប់គ្រាន់ផង ដើម្បីនឹងហ៊ានធ្វើសេចក្ដីស្នើការ ដែលកូនឯងប្រាថ្នាចង់ឱ្យម្ដាយធ្វើនោះ ។ រឿងនេះ នឹងកើតមានឡើងដោយពិតណាស់ ឬមួយព្រះបាទស៊ុលតង់នឹងចំអកឡកឡឺយឱ្យម្ដាយ នឹងបណ្ដេញម្ដាយចេញ ដោយថាម្ដាយឆ្កួត ឬមួយព្រះអង្គនឹងទ្រង់ក្រោធខ្ញាល់ ។ បើដូច្នេះ គឺយើងទាំងពីរនាក់នេះហើយ ដែលជាអ្នកត្រូវទទួលគ្រោះថ្នាក់ដោយជៀសពុំរួចឡើយ ។

មិនតែប៉ុណ្ណោះ. ម្ដាយអាឡាដាំងបានទាញហេតុផលប្រាប់កូនជាច្រើនទៀត ដើម្បីឱ្យវាផ្លាស់មនោសញ្ចេតនាដ៏ចម្លែកនោះចេញ ប៉ុន្តែសម្រស់ព្រះនាងបាឌ្រូលប៊ូឌួរ បានចូលទៅមុតក្នុងបេះដូងអាឡាដាំងជ្រៅណាស់ទៅហើយ គេមិនអាចទាញយុវជនឱ្យងាកចេញពីអន្លង់ស្នេហានេះបានឡើយ ។ អ្នកគិតតែពីបង្ខំម្ដាយឱ្យប្រតិបត្តិការនេះតាមបំណងរបស់ខ្លួន ។ ដោយទឹកចិត្តទន់ភ្លន់របស់មាតាទាំងឡាយដែលតែងតែមានចំពោះបុត្រស្ងួន. ខ្លាចក្រែងបុត្រមិនព្រមលះបង់ចេញពីគំនិតដ៏អំពល់ចិត្តនេះ. ស្ត្រីមេម៉ាយក៏ដាក់ចិត្តកាត់អៀនខ្មាសព្រមធ្វើតាមឆន្ទៈរបស់បុត្រគាត់ ។

វរល់តែជជែកគ្នា ពេលត្រូវចូលវាំងដើម្បីគាល់ព្រះបាទស៊ុលតង់

ក្នុងថ្ងៃនេះ ក៏កន្លងហួសទៅ, កិច្ចការក៏ត្រូវលើកទៅថ្ងៃស្អែក។ តពីនោះ, ម្ដាយនិងកូនក៏ពិភាក្សាគ្នាលេងពីរឿងផ្សេងៗ ដរាបដល់ល្ងាច ។ ចំណែកអាឡាដាំងក៏ខិតខំយកចិត្តទុកដាក់ និយាយប្រាប់ម្ដាយ អំពីរឿងដែលខ្លួនយើងទាំងអម្បាលម៉ាន ប្រយោជន៍អះអាងបន្ថែមប្រាប់ម្ដាយអំពីមុខការដែលគាត់ត្រូវទទួលចូលទៅគាល់ព្រះបាទស៊ុលតង់ ដោយអំណាចវិចារណញ្ញាណនៃកូន, នាងជាម្ដាយក៏ជឿជាក់ថា គាត់មិនមែនពុំអាចសម្រេចកិច្ចការនេះបានទេ ។ តែការពិត, យើងត្រូវដឹងថាគាត់នៅតែមានសេចក្ដីស្ទាក់ស្ទើរគ្រប់កន្លែងទាំងអស់ ។ ហេតុនេះហើយបានជាគាត់និយាយទៅកាន់បុត្រគាត់ដូច្នេះថា : “បើសិនជាព្រះបាទស៊ុលតង់ទទួលម្ដាយដោយស្ម័គ្រដូចបំណងមែន, ហើយបើសិនជាព្រះអង្គទ្រង់ព្រះសណ្ដាប់ នូវសេចក្ដីស្នើសុំដែលកូនឯងប៉ងឱ្យម្ដាយធ្វើនោះសព្វគ្រប់ទៅ ព្រះអង្គទ្រង់ស្ងៀម នោះមិនជាការអ្វីទេ ។ តែបើក្រោយពីព្រះរាជបដិសណ្ឋារកិច្ចនេះមក ព្រះអង្គមិនទ្រង់សួររកកូនឯងសិន ទ្រង់សួររកឯទ្រព្យសម្បត្តិមាសប្រាក់កែវកងនឹងមុខរបររកស៊ីរបស់ឯងមុន ព្រោះថាព្រះអង្គមុខជាទ្រង់ចង់ជ្រាបរឿងនេះ មុនរឿងឯទៀតទាំងអស់ហើយ, តើកូនឯងឱ្យម្ដាយឆ្លើយទូលទៅព្រះអង្គដូចម្ដេច?” ។

អ្នកម្ដាយ, (អាឡាដាំងឆ្លើយ) យើងពុំត្រូវព្រួយមុនឱ្យសោះ កិច្ចការនេះប្រហែលជាមិនកើតហេតុដូច្នេះទេ ។ បើសិនជាព្រះអង្គ



ទ្រង់ចង់ជ្រាបអំពីកិច្ចការផ្សេងៗដែលអ្នកម្ដាយ ទើបនឹងមានប្រសាសន៍អម្បាញ់មិញនេះ, កូននឹងរកចម្លើយមួយ ដែលកូនត្រូវឆ្លើយទូលព្រះអង្គនោះ ។ យើងបានអ្វីៗ ចិញ្ចឹមជីវិតរស់រានអស់ពេលជាយូរឆ្នាំមកហើយ មិនគឺដោយសារមានចង្កៀងជាមធ្យោបាយសម្រាប់រក, ដូច្នេះ កូនជឿជាក់ថា ចង្កៀងនេះនឹងមិនខានផ្ដល់សេចក្ដីត្រូវការដល់កូនទៀតឡើយ ។

ស្ត្រីជាម្ដាយ គ្មានការអ្វីឆ្លើយតបនឹងសេចក្ដីដែលកូនគាត់បាននិយាយនោះសោះ ព្រោះពីមុនមកគាត់យល់ឃើញថា ចង្កៀងដែលកូនគាត់ ពោលនេះអាចផ្ដល់បានត្រឹមតែគ្រឿងសម្រាប់បរិភោគប៉ុណ្ណេះទេ ។ ការនេះធ្វើឱ្យគាត់មានសេចក្ដីសោមនស្សពន់ពេកប្រាសចាកនូវឧបស័គ្គទាំងឡាយ ដែលអាចញាំងឱ្យគាត់គេចខ្លួនចេញអំពីមុខងារដែលគាត់សន្យាថានឹងបំពេញឱ្យកូនគាត់ ដោយត្រូវចូលទៅគាល់ព្រះបាទស៊ុលតង់ ។ អាឡាដាំងយល់គំនិតមាតាដូច្នេះក៏ពោលថា : “អ្នកម្ដាយ ! ទោះបីយ៉ាងម៉េចក៏ដោយ សូមឱ្យអ្នកម្ដាយលាក់រឿងអាថ៌កំបាំងនេះឱ្យជិត ។ លទ្ធផលល្អៗ ដែលអ្នកម្ដាយនឹងខ្ញុំត្រូវបានទទួលអំពីកិច្ចការនេះ អាស្រ័យលើចង្កៀងនេះហើយ” ។ បន្ទាប់ពីនោះ, អាឡាដាំងនឹងម្ដាយក៏បែកគ្នា ដើម្បីទៅរកកន្លែងសម្រាក។ ប៉ុន្តែដោយសេចក្ដីស្នេហាដ៏មោះមុត និងមហាបំណងចំពោះសម្បត្តិដ៏អស្ចារ្យនេះ បានចូលទៅដេកត្រាំពេញខួរក្បាលបុរស ធ្វើឱ្យបុរសឥតបាននិទ្រា

លក់ស្រួលដូចសេចក្តីប្រាថ្នាឡើយ ។ បុរសក្រោកឡើងមុនថ្ងៃនេះ រួចក៏ដើរទៅដាស់ម្តាយភ្លាមតឿនឱ្យគាត់ស្លៀកពាក់ខោ អាវយ៉ាងប្រញាប់ ដើម្បីនឹងបានទៅដល់ខ្លោងទ្វារព្រះរាជវាំង រួចចូលទៅក្នុងនៅពេលគេបើកទ្វារ ដំណាលគ្នានឹងពេលនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីឯទៀត និងនាម៉ឺនសព្វមុខមន្ត្រីទាំងឡាយក្នុងព្រះរាជនគរចូលទៅប្រជុំ ព្រោះនៅពេលប្រជុំនេះ ព្រះបាទស៊ុលតង់តែងទ្រង់យាងមកផ្ទាល់ព្រះអង្គឯង ។

ម្តាយអាឡាដាំង ព្រមធ្វើតាមបំណងកូនគាត់ទាំងអស់ ។ គាត់ចាប់យកចានពរ្សីឡែនដែលមានរបស់ដង្វាយពេញ, រុំនឹងកំណាត់សំពត់ពីរជាន់, មួយជាន់ស្តើងស្អាត, មួយជាន់ទៀតក្រាស់បន្តិចចងជាមុំបួនប្រយោជន៍ឱ្យស្រួលយួរ ។ រួចគាត់ចេញដំណើរទៅតាមផ្លូវ ឆ្ពោះទៅកាន់ផ្លូវព្រះបរមរាជវាំងព្រះបាទស៊ុលតង់ ។ ឃើញដូច្នេះ អាឡាដាំងមានសេចក្តីសោមនស្សជាក្រៃលែង ។ នៅពេលដែលគាត់ទៅដល់នោះលោកនាយករដ្ឋមន្ត្រី ដែលមានរដ្ឋមន្ត្រីឯទៀតហែហមផង និងអស់លោកដែលមានបណ្តាស័ក្តិធំៗ នៅក្នុងព្រះរាជវាំង បានអញ្ជើញចូលទៅក្នុងព្រះរាជវាំងអស់ហើយ មានមនុស្សកុះករជាច្រើន ដែលសុទ្ធតែជាអ្នកមានការដូចគ្នាឈរនៅត្រៀបត្រា ។ លុះឃើញស្ត្រីមេម៉ាយមុស្លាហ្វា គេក៏បើកផ្លូវឱ្យ, គាត់ក៏ដើរចូលរហូតទៅដល់កន្លែងប្រជុំគឺជាបន្ទប់សម្រាប់ទទួលភ្ញៀវមួយយ៉ាងស្អាតបំផុត ហើយទូលាយផង,



មានមាត់ផ្លូវចូលធំល្អវិចិត្រ ។ ចូលទៅដល់ គាត់ក៏ឈប់រកកន្លែងអង្គុយ ដើម្បីឱ្យបានបែរមុខទៅចំព្រះភក្ត្រព្រះបាទស៊ុលតង់ ។ លោកនាយករដ្ឋមន្ត្រីនៅខាងស្តាំ នាម៉ឺនឯទៀតនៅខាងឆ្វេង ។ គេហៅមួយក្រុមម្តងៗ ឱ្យចូលជាលំដាប់តាមលិខិតសុំ ។ កិច្ចការទាំងឡាយរបស់គេ ក៏បានយកទៅពិភាក្សាតវ៉ា វិនិច្ឆ័យរកខុសរកត្រូវ, លុះត្រាចប់សម័យប្រជុំតាមធម្មតា ។ លុះចប់ពេលប្រជុំហើយ ព្រះបាទស៊ុលតង់យាងចាកព្រះទែន មានព្រះរាជបន្ទូលបិទសម័យប្រជុំ ទើបព្រះអង្គយាងចូលទៅក្នុងព្រះរាជក្រឡាបន្ទំ ដោយមានលោកនាយករដ្ឋមន្ត្រីហែព្រះអង្គទៅផង ។ ពួកមន្ត្រីទាំងឡាយក៏អញ្ជើញចេញទៅកាន់ទីកន្លែងរៀងៗខ្លួន ។ រីឯអស់លោកដទៃដែលអញ្ជើញមកក្នុងពេលប្រជុំនេះដែរ, ដោយមានកិច្ចការផ្ទាល់ខ្លួនដោយឡែកៗ ក៏អញ្ជើញថយចេញដែរ, ខ្លះសប្បាយនឹងលទ្ធផលនៃពាក្យបណ្តឹងរបស់ខ្លួន, ខ្លះមានសេចក្តីទោមនស្សតូចចិត្តនឹងការកាត់ក្តីនៃរឿងរបស់ខ្លួន, ខ្លះទៀតមានសេចក្តីសង្ឃឹមថា រឿងរបស់ខ្លួននឹងត្រូវបានគេយកទៅជំនុំជម្រះនៅពេលប្រជុំលើកក្រោយ ។

ម្តាយអាឡាដាំង លុះក្រឡេកឃើញព្រះបាទស៊ុលតង់យាងចេញពីទីនោះ ក៏យល់ច្បាស់ថា ក្នុងទិវានេះ ព្រះអង្គលែងយាងត្រឡប់មកទីនេះវិញហើយ ព្រោះអ្នកឯទៀតក៏គេអញ្ជើញចេញទៅដែរ ។ ដូច្នេះគាត់ក៏ត្រូវត្រឡប់ទៅគេហស្ថានគាត់វិញ ។ ពោលពីអាឡាដាំង

កាលបើឃើញម្ដាយត្រឡប់មក ព្រមទាំងមានកាន់ដង្វាយដែលត្រូវថ្វាយស្ដេចយកមកជាមួយផង ក៏គ្មានគិតចង់ដឹងរឿងអ្វីក្រៅពីលទ្ធផលនៃដំណើរនេះឡើយ ។ នៅក្នុងសេចក្ដីបារម្ភខ្លាចក្រែងម្ដាយមានរឿងអាក្រក់និយាយប្រាប់ខ្លួន យុវជនក៏ពុំហ៊ានហាមាត់សួរម្ដាយអំពីដំណើរនេះឡើយ ។ ម្ដាយអាឡាដាំង ដែលពុំធ្លាប់បានជាន់ដីក្នុងកំពែងវាំងម្ដងសោះ ហើយទាំងពុំដឹងថា តើគេធ្វើអ្វីខ្លះនៅក្នុងព្រះបរមរាជវាំងផង លុះគាត់ត្រឡប់មកវិញក៏អរកខិបកខុប ញ៉ាំងកូនគាត់ឱ្យងាកចេញអំពីសេចក្ដីអំពល់ចិត្តបាន ដោយមានវាចាប្រកបដោយសេចក្ដីលង់ខ្លៅទៅកាន់បុត្រថា: "កូនអើយ! ម្ដាយបានឃើញព្រះបាទស៊ុល-តង់ហើយ ម្ដាយជឿជាក់ថា ព្រះអង្គក៏ទ្រង់ទតឃើញម្ដាយដែរ ។ ម្ដាយអង្គុយនៅចំព្រះភក្ត្រព្រះអង្គ គ្មាននរណាមួយនៅបាំងមុខម្ដាយទេ ប៉ុន្តែដោយព្រះអង្គទ្រង់រវល់នឹងស្ដាប់ពួកអ្នកចូលទៅគាល់ ទូលពីស្ដាំពីឆ្វេងខ្លាំងពេក ធ្វើឱ្យម្ដាយមានសេចក្ដីករុណាចំពោះព្រះអង្គជាខ្លាំងរកតែទូលព្រះអង្គពីរឿងកូនឯងពុំកើត ដោយឃើញព្រះអង្គលំ-បាកព្រះកាយ អត់ធ្មត់ចាំទ្រង់ព្រះសណ្ដាប់នូវសេចក្ដីទូលផ្សេងៗនោះ ។ ការនេះប្រព្រឹត្តទៅអស់ពេលជាយូរ ។ លុះដល់ចប់. ម្ដាយនឹក ស្មានថាប្រហែលជាព្រះអង្គទ្រង់អស់ព្រះកាយពលហើយ. ព្រោះព្រះអង្គទ្រង់យាងចេញពីទីប្រជុំ ដោយឥតឱ្យដំណឹងជាមុនសោះ ហើយយាងចេញពីទីនោះមួយរំពេចទ្រង់ធ្វើហាក់ដូចជាមិនត្រូវការនឹងព្រះសណ្ដាប់នូវ



សេចក្ដីក្រាបបង្គំទូលនៃជនផ្សេងទៀតដែលនៅអង្គុយដង្ហែគ្នា ចាំដល់វេនខ្លួននឹងទូលឡើយ ។ ករណីនេះ ធ្វើឱ្យម្ដាយមានសេចក្ដីរីករាយជាពន់ពេក ។ តែក្រោយមកម្ដាយក៏រសេះរសោះដៃជើងអស់កម្លាំងជាខ្លាំងដោយនៅឈរយូរដូច្នេះ ប៉ុន្តែឥតមានថ្លស់ការអ្វីទេ ស្អែកម្ដាយនឹងទៅទៀតពុំខានឡើយ ។ ព្រះបាទស៊ុលតង់ក៏ប្រហែលជាទ្រង់មិនសូវរវល់ការដែរ" ។

ទោះអាឡាដាំង មានសេចក្ដីស្នេហាចំពោះម្ដាយខ្លួនយ៉ាងណាក៏ដោយ ក៏នៅតែមានសេចក្ដីរកាំរកូសនឹងពាក្យដោះសាររបស់ម្ដាយពិបាកចិត្តនឹងទ្រាំចាំស្ដាប់រឿងនេះតទៅទៀត ។ ប៉ុន្តែយ៉ាងហោចក៏បុរសមានសេចក្ដីសោមនស្សខ្លះដែរ ដោយឃើញម្ដាយបានត្រាយផ្លូវយ៉ាងលំបាកផុតហើយ គឺគាត់បានចូលទៅផ្ទាល់នឹងព្រះភក្ត្រព្រះបាទស៊ុលតង់ហើយតទៅ បុរសមានសង្ឃឹមថាដោយយកតម្រាប់តាមជនទាំងឡាយ ដែលបាននិយាយការទូលព្រះបាទស៊ុលតង់ នៅចំពោះមុខគាត់នោះៗ គាត់នឹងលែងមានសេចក្ដីញញើតនឹងបំពេញករណីយកិច្ចគាត់ហើយ កាលបើកាលៈទេសៈល្អបានបើកឱ្យគាត់ស្នើទូលព្រះអង្គ ។

ស្អែកឡើង. ភ្ញាក់ពីយប់ជាងថ្ងៃមុន ម្ដាយអាឡាដាំងអញ្ជើញឆ្ពោះទៅព្រះបរមរាជវាំងព្រះបាទស៊ុលតង់ទៀត ដោយយកទាំងដង្វាយដដែលនោះទៅផង ប៉ុន្តែឥតប្រយោជន៍សោះ គាត់ឃើញទ្វារព្រះបរមរាជវាំងបិទជិត គាត់ដឹងភ្លាមថា ពេលប្រជុំគណៈរដ្ឋមន្ត្រី ត្រូវធ្វើក្នុង

ពេលពីរថ្ងៃម្តង ដូច្នេះថ្ងៃក្រោយចាំមកទៀត ។ គាត់ក៏ត្រឡប់ទៅផ្ទះវិញនាំដំណឹងនេះទៅប្រាប់កូនគាត់ ដែលត្រូវខំអត់ធ្មត់ចិត្តជាថ្មីទៀត។ ម្តាយអាឡាដាំងបានមកកាន់ព្រះបរមរាជវាំង៦ដងទៀត គឺមកអង្គុយនៅចំព្រះភក្ត្រព្រះបាទស៊ុលតង់ដដែល តែបានលទ្ធផលបន្តិចបន្តួចដូចជាលើកមុនដូច្នោះឯង ។ បើសិនជាព្រះបាទស៊ុលតង់ ទ្រង់ទតឃើញម្តាយអាឡាដាំងរៀងរាល់ពេលប្រជុំ តែព្រះអង្គមិនរវល់អើពើសួរគាត់សោះនោះៗ, ទោះជាគាត់មក ១០០ដើងទៀតក៏ដោយ ក៏នៅតែឥតបានការអ្វីទាំងអស់ ។ ការណ៍នេះនឹងសម្រេចបានភ្លាម ចំពោះតែជនណាដែលនៅជិតព្រះបាទស៊ុលតង់ ហើយដែលមានពាក្យបណ្តឹងថ្វាយព្រះអង្គរៀងៗខ្លួនផង ហើយក្នុងពាក្យនោះមានសេចក្តីសារស័ព្ទកើតទុក្ខពុំសុខចិត្តពីរឿងអ្វីមួយឱ្យច្បាស់លាស់ទៀតផង ។ ចំណែកម្តាយអាឡាដាំង មិនមែននៅក្នុងករណីយនេះទេ ។

ប៉ុន្តែនៅថ្ងៃដែលគាត់ទៅក្រោយនោះ, ព្រះបាទស៊ុលតង់ក្រោយដែលបានបិទសម័យប្រជុំ, ទ្រង់ស្តេចយាងទៅកាន់ព្រះរាជដំណាក់, រួចក៏ទ្រង់ត្រាស់សួរទៅលោកនាយករដ្ឋមន្ត្រីថា “លោកអស់ពេលជាច្រើនដងមកហើយ ដែលខ្ញុំសង្កេតឃើញស្ត្រីម្នាក់មកក្នុងទីនេះរៀងរាល់ថ្ងៃ ដែលយើងទៅប្រជុំ ហើយស្ត្រីនោះមានរបស់មួយរុំនឹងស្បៃស្តើងផង ។ គាត់នៅអង្គុយចំមុខយើង ចាប់តាំងពីពេលបើកសម័យប្រជុំ រហូតដល់ពេលបិទសម័យប្រជុំ ។ តើលោកជ្រាបទេ ស្ត្រីនោះមានការអ្វី? ” ។



លោកនាយករដ្ឋមន្ត្រីក៏ឥតបានជ្រាបរឿងនេះ ឱ្យហួសពីព្រះ-បាទស៊ុលតង់ដែរ ប៉ុន្តែលោកពុំព្រមឆ្លើយថាពុំដឹង, ទើបទូលព្រះករុ-ណាថា : “លម្អងធូលីព្រះបាទក៏គង់ទ្រង់ជ្រាបដែរថា ស្ត្រីៗជាញឹកញយបំផុតហើយ ច្រើនតែយំយែកតម្អូញតម្អែអំពីរឿងដែលឥតមានប្រ-យោជន៍អ្វីសោះនោះ ដូចយ៉ាងស្ត្រីមួយពីថ្ងៃមុនមកយំយែកនៅចំពោះព្រះភក្ត្រព្រះអង្គកើតទុក្ខពុំសុខចិត្តពីរឿងគេលក់ម្សៅធ្វើនំឱ្យមិនល្អឬក៏មកអំពីរឿងផ្សេងទៀតដែលខុសឆ្គងឥតសមហេតុផលសោះ” ។ ព្រះបាទស៊ុលតង់មិនសព្វព្រះរាជហឫទ័យនឹងចម្លើយនេះសោះ ក៏ទ្រង់មានព្រះរាជឱង្ការឡើងថា : “នៅថ្ងៃប្រជុំលើកក្រោយ បើឃើញស្ត្រីនេះមកទៀត ចូរលោកកុំខានឱ្យសោះហៅគាត់ឱ្យចូលមក ដើម្បីឱ្យយើងបានស្តាប់គាត់ផ្ទាល់” ។ លោកនាយករដ្ឋមន្ត្រីឥតមានឆ្លើយអ្វីទាំងអស់លោកថើបដៃលោក រួចលើកទូលដាក់លើក្បាលជាសញ្ញាឱ្យដឹងថា លោកនឹងទទួលទោសដល់ជីវិត បើសិនជាលោកពុំបានប្រតិបត្តិតាមព្រះរាជបញ្ជានៃព្រះបាទស៊ុលតង់ ។

ដំណាលពីម្តាយអាឡាដាំង ដោយគាត់ធ្លាប់បានចូលទៅគាល់ព្រះបាទស៊ុលតង់ជាញឹកញយបន្តិចហើយ ក៏លែងនឹកព្រួយបារម្ភអ្វីទៀតឡើយ ថែមទាំងបានប្រាប់កូនឱ្យដឹងជាមុនថា គាត់នឹងមិនភ្លេចនិយាយកិច្ចការនេះទូលព្រះអង្គឱ្យទាល់តែទ្រង់យល់ស្របតាម។ ដូច្នេះស្អែកឡើង គេឃើញម្តាយអាឡាដាំង អញ្ជើញទៅព្រះបរមរាជវាំងទៀត គាត់អង្គុយត្រង់កន្លែងធម្មតា ទល់នឹងព្រះភក្ត្រព្រះបាទស៊ុលតង់។

លោកនាយករដ្ឋមន្ត្រីពុំទាន់នាំសេចក្ដីណាមួយទៅទូលព្រះអង្គផង, ស្រាប់តែព្រះបាទស៊ុលតង់យាងមកដល់ ។ ទោរទន់ទៅដោយចិត្តករុណា ដែលបានដេកត្រាំនៅក្នុងហទ័យវត្ថុព្រះអង្គជាយូរមកហើយ ព្រះរាជបន្ទូលទៅកាន់លោកនាយករដ្ឋមន្ត្រីថា : "ក្រែងលោកភ្លេច, មុនដំបូងបង្អស់ ខ្ញុំសូមជម្រាបលោកថាស្ត្រីនេះហើយ ដែលខ្ញុំទើបនឹងដំណាលប្រាប់លោក ។ ចូរលោកហៅគាត់ចូលមក រួចយើងចាំស្ដាប់គាត់និយាយ ដើម្បីនឹងសម្រេចការនេះឱ្យបានឆាប់ជូនគាត់ ។ ក្នុងពេលមួយរំពេចនោះលោកនាយករដ្ឋមន្ត្រី ចង្អុលប្រាប់ទៅនាយតម្រួតដែលឈរចាំទទួលបង្គាប់ឱ្យទៅដឹកដៃនាំស្ត្រីនោះចូលមក ។

នាយតម្រួត ក៏ដើរតម្រង់ទៅម្ដាយអាឡាដាំងធ្វើសញ្ញាឱ្យគាត់ចូលមក ។ ឃើញសញ្ញានេះភ្លាម, ស្ត្រីមេម៉ាយ ក៏ដើរតាមនាយតម្រួត រហូតទៅដល់ទៀបនឹងព្រះរាជបល្ល័ង្កព្រះបាទស៊ុលតង់ ។ ទៅដល់ទីនោះ នាយតម្រួតក៏ថយចេញ ទុកឱ្យគាត់អង្គុយនៅជិតលោកនាយករដ្ឋមន្ត្រី ។

ម្ដាយអាឡាដាំង, ដោយបានឃើញរបៀបអ្នកមុខគេធ្វើយ៉ាងណាខ្លះនោះក្នុងការចូលទៅគាល់ព្រះមហាក្សត្រ, គាត់ក៏យកតម្រាប់តាមនោះដែរ ដោយឱនក្បាលក្រាបផ្ទាល់ទៅលើកម្រាល ដែលក្រាលលើជណ្ដើរបល្ល័ង្ករាជ្យ លុះត្រាតែព្រះបាទស៊ុលតង់មានព្រះរាជឱង្ការឱ្យងើបឡើង ទើបគាត់ងើប ។ ពេលនោះព្រះបាទស៊ុលតង់ក៏មានព្រះ



បន្ទូលមកកាន់គាត់ថា: "នែអ្នកម្ដាយអើយ ! អស់ពេលជាយូរហើយ យើងតែងឃើញអ្នកម្ដាយចូលមក កន្លែងនេះហើយទ្រាំនៅតាំងពីពេលបើកសម័យប្រជុំរហូតដល់បិទ ។ តើអ្នកម្ដាយមានការអ្វី ?"

ក្រោយដែលបានស្ដាប់ព្រះរាជសាសន៍រួច ស្ត្រីមេម៉ាយក៏ឱនក្បាលក្រាបវន្ទាម្ដងទៀត ។ លុះងើបឡើងគាត់ក៏ពោលថា: "សូមព្រះតេជៈដ៏កល់លើត្បូង ដែលជាធំលើក្សត្រទាំងឡាយក្នុងលោក មុននឹងក្រាបទូលលួងធូលីព្រះបាទ ពីរឿងដ៏ចម្លែកហើយស្ទើរតែពុំអាចជឿបាន ដែលធ្វើឱ្យខ្ញុំម្ចាស់ហ៊ានចូលមកផ្ទាល់នឹងព្រះអង្គនេះ ខ្ញុំម្ចាស់សូមឱ្យព្រះអង្គទ្រង់ព្រះរាជទានអភ័យទោសជាមុន ចំពោះចិត្តព្រើលរបស់ខ្ញុំម្ចាស់នេះ ប្រយោជន៍ឱ្យខ្ញុំម្ចាស់ មានសេរីភាពបរិបូណ៌នឹងថ្លែងថ្វាយព្រះអង្គដោយឥតញញើត, រឿងនេះខុសពីគេឯទៀតទាំងអស់ ។ ខ្ញុំម្ចាស់មានសេចក្ដីតក់ស្លុត និងអៀនខ្មាសជាក្រៃលែងក្នុងការស្នើទូលព្រះអង្គនេះ" ។ ដើម្បីបើកសេរីភាពឱ្យនាងបាននិយាយគ្រប់គ្រាន់, ព្រះបាទស៊ុលតង់ក៏ទ្រង់ព្រះរាជបញ្ជាឱ្យអស់នាម៉ឺនសព្វមុខមន្ត្រី ទាំងឡាយអញ្ជើញចេញទាំងអស់ ទុកឱ្យនៅតែលោកនាយករដ្ឋមន្ត្រីមួយរូបប៉ុណ្ណោះ ទើបព្រះអង្គមានព្រះបន្ទូលទៅកាន់ស្ត្រីនោះថា : អ្នកអាចនិយាយដោយសេរី ហើយកុំបីកោតញញើត ឬបារម្ភអ្វីឱ្យសោះ ។

ទុកជាដូច្នេះក៏ដោយ, ម្ដាយអាឡាដាំងក៏នៅតែពុំទាន់អស់អញ្ញនិងសេចក្ដីសប្បុរសនៃព្រះបាទស៊ុលតង់សោះ ដែលទ្រង់មានព្រះ-

មេត្តាធមិអាណិតខ្លួនមិនឱ្យនិយាយការទូលព្រះអង្គនៅចំពោះមុខរដ្ឋមន្ត្រីទាំងឡាយ ក្រែងលោការនេះអាចនាំសេចក្ដីទុក្ខដល់ខ្លួន។ គឺគាត់ប្រាថ្នាចង់សុំឱ្យព្រះអង្គទ្រង់ព្រះរាជទានទោសជាដាច់ខាតផងទៀត ទោះជារឿងនោះមានរបៀបយ៉ាងណាក៏ដោយ។ គាត់ពោលយ៉ាងនេះព្រោះយល់ថា រឿងគាត់នេះ ព្រះអង្គមុខជាទ្រង់ភ្ញាក់ផ្អើលព្រះទ័យពុំខាន។ ដូច្នេះហើយ ទើបគាត់ពោលបន្ថែមថា: "ព្រះករុណាថ្លៃវិសេស ខ្ញុំម្ចាស់សូមឱ្យទ្រង់ព្រះរាជទានមេត្តាទោសជាមុន ចំពោះសេចក្ដីដែលខ្ញុំម្ចាស់នឹងទូលថ្វាយ ទោះជាសេចក្ដីនោះប៉ះពាល់ពុំសមគួរសូម្បីតែបន្តិចបន្តួចក៏ដោយ"។ ព្រះបាទស៊ុលតង់ក៏មានព្រះបន្ទូលតបវិញថា: "ទោះជារឿងនោះយ៉ាងដូចម្ដេចក៏ដោយ, យើងអនុញ្ញាតទោសឱ្យអ្នកម្ដាយទាំងអស់ តាំងពីពេលនេះទៅ ហើយគ្មានការអ្វីអាចឱ្យអ្នកមានសេចក្ដីឈឺចាប់ សូម្បីតែបន្តិចក៏ទេដែរ ចូរអ្នកម្ដាយនិយាយដោយសេចក្ដីក្លាហានចុះ"។

ម្ដាយអាឡាដាំង, ក្រោយដែលបានប្រុងប្រៀបខ្លួនឱ្យសមជាស្ត្រី ដែលមានសេចក្ដីខ្លាច ចំពោះការក្រោធខឹងនៃព្រះបាទស៊ុលតង់ អំពីសេចក្ដីស្នេហ៍មួយយ៉ាងវិសេសជាងសេចក្ដីដែលគាត់បាននិយាយ ទូលពីមុននេះទៀត, គាត់ក៏ពោលរាប់រៀបទូលព្រះអង្គដោយភក្ដីភាព តាំងពីពេលដែលអាឡាដាំងបានឃើញព្រះនាងបាឌ្រូលប៊ូឌូរ, អំពីសេចក្ដីថ្លែងការផ្សេងៗ ដែលអាឡាដាំងកូនគាត់បានបំភ្លឺគាត់ និងអំពី



រឿងទាំងឡាយឯទៀតទាំងអស់ ដែលគាត់បានពោលបង្ហាញយុវជន ដើម្បីឱ្យយុវជនងាកបែរចេញពីតណ្ហា ដែលមិនគ្រាន់តែអាស្រូវភាសដល់ព្រះអង្គមួយទេ គឺអាស្រូវភាសដល់ព្រះនាងព្រះរាជបុត្រីព្រះអង្គទៀត។ សេចក្ដីដែលគាត់ថ្លែងដូចមានតទៅនេះ : "ប៉ុន្តែកូនប្រុសខ្ញុំម្ចាស់ នឹងមិនព្រមយល់នូវសេចក្ដីព្រហើនរបស់ខ្លួនជាដាច់ខាតវាងប់ចិត្តគិតតែពីរឿងនេះរហូតដល់មកបង្ខំខ្ញុំម្ចាស់ ឱ្យចូលមកដណ្ដឹងព្រះនាងជាព្រះរាជបុត្រីព្រះអង្គ ដើម្បីរៀបអាពាហ៍ពិពាហ៍ដោយបញ្ចេញអាកប្បកិរិយា នៃការអស់សង្ឃឹមឱ្យខ្ញុំម្ចាស់ឃើញទៀតផង បើសិនជាខ្ញុំម្ចាស់ប្រកែកពុំព្រមធ្វើតាមបំណងវា ។ ខ្ញុំម្ចាស់សែនមហាលំបាកចិត្តជាក្រៃលែង ក្នុងការចូលមកស្នើនឹងព្រះអង្គនេះ តែនេះគ្រាន់ជាការបំពេញបំណងរបស់បុត្រខ្ញុំម្ចាស់ប៉ុណ្ណោះ ។ ហេតុនេះ ខ្ញុំម្ចាស់សូមអង្វរព្រះអង្គម្ដងទៀត សូមឱ្យព្រះអង្គទ្រង់ព្រះរាជទានទោសមិនត្រឹមតែលើរូបខ្ញុំម្ចាស់ទេ គឺលើរូបកូនខ្ញុំម្ចាស់ទៀត ដែលមានគំនិតយល់ឆ្វេងប្រាថ្នាចងស្ពានមេត្រីដ៏ខ្ពស់ហួសប្រមាណយ៉ាងនេះ,ឥតមើលឋានៈខ្លួន" ។

**ចប់ភាគទី៣៩ តែប៉ុណ្ណេះ**

**រឿងនេះនៅមានតទៅភាគទី៤០ ទៀត សូមអស់លោក-អ្នក កុំភ្លេចជាវយកទៅអានឱ្យសោះ ព្រោះក្នុងភាគនោះមានក្រសែទាក់ទងគ្នាមានសេចក្ដីប្លែកៗពីរោះអស្ចារ្យគួរឱ្យចាប់អារម្មណ៍ណាស់ ។**

# រឿងអាឡាដាំង ឬចង្កៀងទិព្វ

(ភាគទី៤០)

ព្រះបាទស៊ុលតង់ ទ្រង់ព្រះសណ្ដាប់រឿងនេះដោយសេចក្ដីសុភាព និងដោយចិត្តធមិគ្មានបញ្ចោញសញ្ញាអ្វី ដែលគួរសម្គាល់ដឹងនូវសេចក្ដីក្រោធ និងសេចក្ដីមិនពេញព្រះទ័យឡើយ ថែមទាំងមិនទ្រង់រវល់រិះគន់ ដល់សេចក្ដីក្រាបទូលនេះផងឡើយ។ ប៉ុន្តែមុននឹងឆ្លើយតបទៅស្ត្រីនោះវិញ ព្រះអង្គទ្រង់ត្រាស់សួរអំពីរបស់ ដែលគាត់យកមកថ្វាយ រុំនឹងកំណាត់សៃ្បនោះ តើជាវត្ថុអ្វី? ។ ម្ដាយអាឡាដាំងក៏ចាប់យកចានពរ្សឺឡែន ដែលគាត់ដាក់នៅទៀបជើងបល្ល័ង្ករាជ្យមុនពេលក្រាបថ្វាយបង្គំព្រះអង្គ មកស្រាយលាបង្ហាញព្រះអង្គទត ។

គេពុំអាចពោលបានឡើយ អំពីការចម្លែកព្រះទ័យនិងការងឿងឆ្ងល់នៃព្រះបាទ ស៊ុលតង់ ដែលកើតមានឡើងនៅពេលដែលព្រះអង្គ ទ្រង់ទតឃើញត្បូងថ្មយ៉ាងសម្បើមដាក់តម្រៀបនៅក្នុងចានពរ្សឺឡែន ដែលជារបស់មានតម្លៃច្រើនឥតគណនា មានពណ៌ភ្លឺផ្លេកគួរឱ្យពិតពិលរមិលមើលមានទំហំប្លែក ដែលព្រះបាទស៊ុលតង់ពុំដែលបានទតឃើញត្បូងណាដូចនេះឡើយ ។ ព្រះអង្គលង់គំនិតស្ងួងទតអច្ឆរិយវត្ថុទាំងនេះអស់ពេលជាយូរ ដោយឥតមានធ្វើចលនាអ្វីទាំងអស់ ។ ក្រោយដែលព្រះអង្គមានស្មារតីដូចធម្មតាឡើងវិញ ព្រះអង្គ

ទ្រង់ទទួលយកដង្វាយ ពីដៃម្ដាយអាឡាដាំង ព្រមទាំងទ្រង់បញ្ចេញព្រះសូរសីហនាទជាខ្លាំងសំដែងនូវសេចក្ដីត្រេកអរថា: “អើ ! នេះបានចំជាល្អចំជាមានតម្លៃក្រៃលែងមែន” ។ លុះទ្រង់បានទត បានចាប់កាន់នៅត្រង់កន្លែង ដែលល្អប្លែកជាងគេ សព្វគ្រប់ទាំងអស់ហើយ ព្រះអង្គក៏ងាកបែរទៅកាន់លោកនាយករដ្ឋមន្ត្រី ចង្អុលបង្ហាញទៅថានដាក់ត្បូងរួចមានព្រះរាជឱង្ការថា : “សូមលោកមើល ហើយសូមលោកយល់ថា គ្មាននរណាអាចមានទេនៅក្នុងលោកនេះរបស់ដ៏មានតម្លៃល្អឥតខ្ចោះនេះ” ។ លោកនាយករដ្ឋមន្ត្រី ក៏ស្រឡាញ់របស់នេះជាក្រៃលែងដែរ ។ “នែលោក ! (ព្រះបាទស៊ុលតង់មានព្រះរាជឱង្ការត) តើលោកមានយោបល់ដូចម្ដេចអំពីដង្វាយនេះ? មិនសមនឹងឋានៈបុត្រីខ្ញុំឬ? ហើយតាមតម្លៃនៃរបស់នេះ តើខ្ញុំមិនអាចលើកបុត្រីខ្ញុំ ឱ្យទៅជនដែលចូលស្ដីដណ្ដឹងឬ?” ។

ព្រះរាជឱង្ការនេះ ធ្វើឱ្យលោកនាយករដ្ឋមន្ត្រីរំជួលចិត្តជាអស្ចារ្យ ព្រោះព្រះបាទស៊ុលតង់ ទើបនឹងមានព្រះរាជឱង្ការប្រាប់លោកថា ព្រះអង្គមានប្រាថ្នានឹងរៀបអភិសេកព្រះរាជបុត្រីព្រះអង្គជាមួយនឹងកូនប្រុសលោក ។ លោកមិនមែនបារម្ភដោយឥតហេតុផលនឹងឆ្លើយនោះទេ គឺបារម្ភខ្លាចក្រែងព្រះបាទស៊ុលតង់ ត្រេកអរហួសប្រមាណ នឹងដង្វាយដ៏ប្រសើរនេះ ក៏ផ្លាស់ប្ដូរព្រះរាជបំណង ដែលទ្រង់បានព្រាងទុកមកពីមុន ។ គិតដូច្នេះហើយ លោកនាយករដ្ឋមន្ត្រី ក៏ខិតចូលទៅជិតព្រះបាទស៊ុលតង់ រួចក៏ខ្សឹបដាក់ព្រះកាណ៌ព្រះអង្គថា “សូមក្រាបបង្គំទូលព្រះករុណាថ្លៃវិសេស ព្រះអង្គអាចប្រកែកបានតែនឹងដង្វាយណា ដែលមិនសមនឹងឋានៈព្រះអង្គម្ចាស់ក្សត្រី ។ប៉ុន្តែទូលព្រះបង្គំសូមអង្វរព្រះអង្គសូមឱ្យទ្រង់អនុញ្ញាតពេល ឱ្យទូលព្រះបង្គំគិតមើល ៣ខែសិន មុននឹងព្រះអង្គសម្រេចរឿងនេះ ។ ទូលព្រះបង្គំសង្ឃឹមថា មុនគ្រប់រយៈពេល៣ខែនេះ កូនទូលព្រះបង្គំមុខជានឹងរកបានរបស់អ្វីមួយថ្វាយព្រះអង្គ ហើយរបស់នោះមានតម្លៃច្រើនជាងរបស់អាឡាដាំង ជាមនុស្សដែលព្រះអង្គពុំធ្លាប់ស្គាល់សោះនោះផង” ។ ព្រះបាទស៊ុលតង់ ទោះបីឈ្វេងយល់ជាមុនថា កូនលោកនាយករដ្ឋមន្ត្រីពុំអាចរករបស់អ្វីឱ្យកូនធ្វើជាដង្វាយ ឱ្យបានប្រសើរគាប់ព្រះទ័យព្រះបាទម្ចាស់ក្សត្រីក៏ដោយ ក៏ព្រះអង្គនៅតែទ្រង់ស្ដាប់ពាក្យអង្វរនោះ ហើយទ្រង់អនុញ្ញាតពេល៣ខែ ដល់លោកនាយករដ្ឋមន្ត្រីក៏ទ្រង់ងាកព្រះភក្ត្រទៅកាន់ម្ដាយអាឡាដាំង រួចមានព្រះបន្ទូលថា : “អ្នកម្ដាយអើយ ! សូមអ្នកម្ដាយត្រឡប់ទៅផ្ទះវិញសិនចុះ ហើយនិយាយប្រាប់បុត្រអ្នកថា យើងទទួលព្រមនូវសេចក្ដីទូលស្នើរបស់អ្នកម្ដាយហើយ ប៉ុន្តែយើងអាចរៀបអភិសេកព្រះរាជបុត្រីយើងបានលុះត្រា តែយើងរកគ្រឿងសង្ហារឹមឱ្យកូនយើងបានសិន គ្រឿងទាំងនេះអាចរៀបចំបានសព្វគ្រប់ លុះត្រាតែអស់ពេល៣ខែ។ ដូច្នេះចាំគ្រប់កំណត់ពេលនេះ សឹមអ្នកម្ដាយត្រឡប់មកម្ដងទៀត” ។

ម្ដាយអាឡាដាំង ត្រឡប់ទៅគេហស្ថានវិញ ប្រកបដោយបីតិសោមនស្ស ជាក្រៃលែង ចំពោះលទ្ធផលនៃបេសកកម្មរបស់គាត់នេះ ព្រោះពីមុនគាត់យល់ថា ការនេះពុំអាចមានលទ្ធភាពឡើយ ឥឡូវនេះមិនត្រូវទទួល ឯការទ្រគោះបោះបោកពីព្រះបាទស៊ុលតង់ ដែលនឹងនាំឱ្យគាត់អាម៉ាស់មុខដូចគាត់ស្មានទុកពីមុននោះ ត្រឡប់ជាបានទទួលនូវព្រះបន្ទូលយល់ស្របតាមគាត់ទៅវិញ ។ ពោលពីអាឡាដាំង លុះឃើញម្ដាយត្រឡប់មកវិញនាំយកដំណឹងល្អមកប្រាប់ ក៏កើតមានការសង្កេតពីរផ្សេងគ្នាឡើងមួយទៀត ដោយឃើញគាត់មានទឹកមុខរីករាយ ។ អាឡាដាំងចាំឱ្យម្ដាយមកដល់ពុំទាន់ ក៏ស្រែកសួរភ្លាមថា: "ម៉េចទៅម៉ាក់ឱ្យខ្ញុំសង្ឃឹមបានទេ? ខ្ញុំត្រូវស្លាប់ដោយសេចក្ដីអស់សង្ឃឹមឬ?" ។ លុះគាត់ដោះស្បៃរុំចេញរួច ទៅអង្គុយលើកៅអីវែងមួយនឹងកូនគាត់ៗ ក៏និយាយឡើងថា: "កូនប្រុសម្ដាយកូនឯងមិនស្លាប់ដោយអស់សង្ឃឹមទេ កូនឯងត្រូវបានសេចក្ដីសប្បាយគ្រប់គ្រាន់" ។ បន្ទាប់មក គាត់ក៏និយាយប្រាប់កូនអំពីរបៀប ដែលគាត់បានចូលទៅផ្ទាល់នឹងព្រះមហាក្សត្រមុនគេ បានជាបានត្រឡប់មកវិញពីព្រលឹមនេះ អំពីការប្រុងប្រៀបខ្លួនចូលទៅគាល់ព្រះអង្គៗ ក៏ឥតមានចាប់ផ្ដាក់អ្វីឡើយ ។ លំដាប់មកគាត់អធិប្បាយ អំពីរឿងរៀបអភិសេកព្រះនាងបាឌ្រូលប៊ូឌូរ ជាមួយនឹងអាឡាដាំង រឿងនេះក៏បានព្រះបាទស៊ុលតង់ឆ្លើយយល់ស្របតាម ។ ម្ដាយអាឡាដាំង បន្ថែមសេចក្ដី



ទៀតថា តាមដែលគាត់សង្កេតឃើញអាការ ព្រះបាទស៊ុលតង់ គាត់យល់ច្បាស់ថា ដង្វាយនេះធ្វើឱ្យពេញព្រះទ័យព្រះអង្គណាស់បានជាព្រះអង្គទ្រង់យល់ស្រប តាមសេចក្ដីក្រាបទូលរបស់ម្ដាយ ។ ប៉ុន្តែម្ដាយមានសង្ឃឹមអូនថយបន្តិចទៅវិញ ដោយឃើញលោកនាយករដ្ឋមន្ត្រីបានខ្សឹបដាក់ព្រះកាណ៌ព្រះអង្គ រួចទើបព្រះអង្គមានព្រះរាជឱង្ការមកម្ដាយជាក្រោយ ។ ម្ដាយបារម្ភខ្លាចក្រែងលោកនាយករដ្ឋមន្ត្រីនិយាយញុះញង់ បំបែរព្រះអង្គឱ្យងាកពីឆន្ទៈល្អនេះជាហេតុបណ្ដាលឱ្យមានផលអាក្រក់ដល់កូនឯង" ។

បានឮដំណឹងដូច្នេះ អាឡាដាំងមានសេចក្ដីត្រេកអរក្រៃលែង បុរសក៏សំដែងអំណរគុណដ៏ជ្រាលជ្រៅដល់ម្ដាយ ដែលបានខំខ្នះខ្នែងបំពេញកិច្ចការនេះឱ្យខ្លួន។ ចំពោះរូបអាឡាដាំង ពេលវេលាបីខែនេះហាក់ដូចជាយូរអង្វែងពេកណាស់ តែទោះបីជាយ៉ាងណាក៏ដោយយុវជនក៏ស៊ូទ្រាំចាំឥតធុញទ្រាន់ឡើយ ព្រោះយុវជនយល់ថា ព្រះរាជសាសន៍ព្រះបាទស៊ុលតង់នេះ ពុំអាចរុះរើផ្លាស់ប្ដូរបានឡើយ ។ ប៉ុន្តែគួរឱ្យអាសូរដល់បុរសកម្សត់ណាស់ ព្រឹត្តិការណ៍ក្នុងលោក តែងផ្លាស់ប្ដូរជារាល់ថ្ងៃ ។ នៅពេលដែលបុរសអង្គុយរាប់ពេល មិនត្រឹមតែម៉ោងថ្ងៃនិងខែទេ រហូតដល់នាទី វិនាទីទៀត ទម្រាំនឹងបានផុតកំណត់ពេល ៣ខែនេះ ។ លុះបានប្រហែលជាពីខែកន្លងផុត ទេសកាលអ្វីល្ងាចមួយម្ដាយអាឡាដាំងនឹកចង់យកចង្កៀងមកអុជ តែដោយចង្កៀងគ្មាន

ប្រេង គាត់ក៏ដើរចេញទៅរកទិញ ។ លុះចូលទៅដល់ក្នុងទីក្រុង គាត់ឃើញអ្នកក្រុងទាំងប៉ុន្មាន កំពុងធ្វើបុណ្យ ។ ហាងលក់ទំនិញទាំងឡាយបើកទ្វារចំហយ៉ាងធំទូលាយ មានចងស្លឹកឈើផ្កាភ្ញីចាលម្អផង មានបើកភ្លើងភ្លឺព្រោងព្រាត គឺថាម្នាក់ៗ ខំធ្វើដូចម្ដេចឱ្យតែគេហស្ថានខ្លួនបានល្អឆើតជាងគេ ដើម្បីបង្ហាញនូវសេចក្ដីឈឺឆ្អាលខ្នះខ្នែងក្នុងការរៀបចំធ្វើបុណ្យនេះ។ បណ្ដាជនទាំងអស់គ្នាប្រកបដោយទឹកមុខរីករាយសប្បាយប្រឹមប្រិយ ។ នៅតាមវិថីទាំងឡាយសោតទៀត គេសង្កេតឃើញនាយទាហានជាច្រើនស្លៀកពាក់ជារបៀបធ្វើបុណ្យអង្គុយនៅលើខ្នងពាជីរៀងៗខ្លួន ហើយមានបាវព្រាវខ្ញុំកំដរទាសាទាសីដើរចុះឡើងកកកុញ ។ ឯពាជីទាំងឡាយនោះទៀត សុទ្ធតែតុបតែងស្អាតចំឡែកណាស់ ។ ឃើញដូច្នេះ ម្ដាយអាឡាដាំងក៏ សួរម្ចាស់ផ្ទះលក់អីវ៉ាន់ ដែលគាត់ចូលទៅទិញអំពីហេតុការណ៍នេះ។ អ្នកលក់ក៏និយាយតបមកវិញថា : “អ្នកស្រី ! អ្នកអញ្ជើញមកពីណា? អ្នកពុំជ្រាបទេ ឬកូនលោកនាយករដ្ឋមន្ត្រី ត្រូវរៀបការល្ងាចនេះ ជាមួយនឹងព្រះនាងបាឌ្រូលប៊ូឌូរ ព្រះរាជបុត្រីព្រះបាទស៊ុលតង់ ។ ឥឡូវព្រះនាងជិតនឹងយាងចេញពីបន្ទប់ស្រង់ទឹកហើយ ឯមន្ត្រីទាំងឡាយដែលអ្នកឃើញនេះ គេឈរធ្វើជាក្បួនអមព្រះនាង រហូតទៅដល់ព្រះបរមរាជវាំងដែលជាកន្លែងធ្វើពិធីនេះ”។

ម្ដាយអាឡាដាំង មិនចង់ជ្រាបរឿងនេះ វែងឆ្ងាយតទៅទៀត



ទេ គាត់ប្រញិបប្រញាប់ កង្វើញសំពត់ដើររត់ៗត្រឡប់ទៅផ្ទះវិញ ហាត់ដកដង្ហើមស្ទើរតែពុំដល់គ្នា ។ទៅដល់គាត់ឃើញកូននៅស្ងៀម ឥតដឹងរឿងនេះសោះ គាត់ក៏ស្រែកឆោឡោឡើងថា : “កូនប្រុសម្ដាយអើយ កូនឯងត្រូវបង់ខាតអស់ហើយ កូនឯងប្រកាន់ខ្ជាប់នូវពាក្យសន្យាព្រះបាទស៊ុលតង់ ។ ឥឡូវនេះគ្មានបានការធ្វីទាំងអស់ ” ។ អាឡាដាំងមានសេចក្ដីរន្ធត់ញាប់ញ័រដូចដើមសោងត្រូវខ្យល់ ក៏សួរម្ដាយឡើងថា : “រឿងហេតុត្រង់ណា ដែលបណ្ដាលឱ្យព្រះអង្គទ្រង់ពុំកាន់ពាក្យសត្យដូច្នេះ? អ្នកម្ដាយបានជ្រាបរឿងដូចម្ដេចខ្លះដែរឬ?” នាងជាម្ដាយក៏ឆ្លើយឡើងថា : “កូនអើយ ! ល្ងាចនេះកូនលោកនាយករដ្ឋមន្ត្រី ត្រូវរៀបការជាមួយនឹងព្រះនាងបាឌ្រូប៊ូឌូរ នៅក្នុងព្រះបរមរាជវាំង” ។ បន្ទាប់មកគាត់ក៏និយាយរឿងដែលគាត់បានដឹងបានឃើញ នេះប្រាប់កូនគាត់សព្វគ្រប់ ។

គ្រាន់តែបានស្ដាប់ដំណឹងនេះភ្លាម អាឡាដាំងទៅជាស្រឡាំងកាំង វិស័យដូចជាត្រូវនឹងគ្រាប់កាំរន្ទះ ។ ប៉ុន្តែសេចក្ដីច្រណែននិន្ទាមួយក៏កើតមានឡើងដាស់ឱ្យបុរសបានដឹងខ្លួនឡើងវិញភ្លាម នឹកឃើញភ្លែតដល់ចង្កៀង ដែលជារបស់មានប្រយោជន៍ដ៏អស្ចារ្យ។ ដោយគ្មានបញ្ចេញអាការៈឬពោលពាក្យអ្វីបន្តិចបន្តួច ដែលជាសញ្ញាឱ្យដឹងថាបុរសមានសេចក្ដីតូចចិត្តនឹងព្រះបាទស៊ុលតង់ ឬលោកនាយករដ្ឋមន្ត្រីក៏ទេសោះដែរ បុរសគ្រាន់តែមានវាចាបន្តិចទៅកាន់មាតាថា : “អ្នក